# ទំលាប់ទំនៀមខ្មែរ



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

អំណោយពីលោក ឡៅ ឃុនសារិន សំរាប់កុមារខ្មែរ ដើម្បី
និងដាក់ទុកក្នុង eLibrary of Cambodia

កក្កដា 2015

# សេចក្ដីផ្ដើម

ខ្ញុំរៀបរៀងទម្លាប់ទំនៀមនេះឡើង ឱ្យត្រូវតាមប្រវេណីស្រុករបស់យើង ដែលខ្ញុំធ្លាប់បានដឹង បានឃើញ ហើយចាំទុកមកតាំងពីខ្ញុំដឹងខុសត្រូវ ។ អ្នកឧកញ៉ា មហាវិនិច្ឆ័យ (នៅ) ជាបិតាខ្ញុំ លោកបានហ្វឹកហ្វឺនខ្ញុំក្នុងរបៀបគារវកិច្ចជាច្រើនជំពូក ។

ដល់ខ្ញុំបានធ្វើការជាគ្រូបង្រៀនខ្ញុំបានចូលគាល់បំរើសម្ដេចព្រះរាជវរយក្សកោវរចក្ររណរិទ្ធិ (**សុធារស**) ។ សម្ដេចក៏ទ្រង់ព្រះមេត្ដាប្រោស ព្រះរាជទានប្រៀនប្រដៅនូវកិច្ចគារវៈផ្សេងៗជាច្រើន ។ ទ្រង់ព្រះរាជទានក្បួនរាជសព្ទ អក្ខរវិធីទាំងរបៀបសរសេរ និង និយាយអោយត្រឹមត្រូវតាមទំរង់សក្ដិ ។

ដល់បក គ.ស ១៩៤៥ ព្រះបាទសម្ដេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះចៅព្រះរាជាណាចក្រកម្ពុជាធិបតី ជាម្ចាស់ជីវិតលើត្បូងទ្រង់ព្រះមេត្ដាប្រោសព្រះរាជទានខ្ញុំអោយធ្វើជាឧកញ៉ាមហាមន្ត្រី ចាងហ្វាងព្រះរាជមន្ទីរក្នុងព្រះបរមរាជវាំង ។ ខ្ញុំបានចូលគាល់បំរើក្រោមព្រះបាទយុគលរៀងមក តែពុំបានឃើញមានច្បាប់ក្បួន របៀបខាងមន្ត្រី និងប្រជារាស្ត្រឡើងក្រាបបង្គំគាល់ព្រះមហាក្សត្រិយ៍ជាម្ចាស់ផែនដី និងខត្តិយត្រកូលផ្សេងៗទុកជាក្បួនមកសោះ ។

ហេតុនេះហើយខ្ញុំតាំងព្យាយាមសរសេរក្បួននេះឡើង ហើយបានបោះពុម្ពជាសៀវភៅទុកគ្រាន់ចែកជនានុជន ដែលពុំបានដឹងសព្វគ្រប់ក្នុងគារវកិច្ច ។ មួយទៀតក្រៅអំពីទម្លាប់ទំនៀមស្រុករបស់យើង ខ្ញុំបានយករបៀបអឺរ៉ុបខ្លះដែលយើងនិយមប្រើដែរ មកបញ្ចូលផង ។

ខ្ញុំខំសរសេរតទៅទៀតក្នុងសៀវភៅភាគទី ២ ។

ឧកញ៉ាមហាមន្ត្រី

ញ៉ិក នូច

www.facebook.com/7khmer
Fbpage : Entertainment And Knowledge

# មាតិកា.


| | | | |
|---|---|---|---|
| ១- | គារវកិច្ច | ទំព័រ | ១ |
| ២- | បុរាណភាសិត | -//- | ២ |
| ៣- | ដំណេក | -//- | ៣ |
| ៤- | ដេក (ឥរិយាបថទី ១) | -//- | ៤ |
| ៥- | អង្គុយ (ឥរិយាបថទី ២) | -//- | ៧ |
| ៦- | ទីអង្គុយផ្លូវការ (ព្រះសង្ឃ) | -//- | ៧ |
| ៧- | ទីអង្គុយ (ព្រហស្ថ-ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ) | -//- | ៩ |
| ៨- | ទីអង្គុយ (តាមអារ្យធម៌អឺរ៉ុប) | -//- | ១១ |
| ៩- | ទីអង្គុយ (តាមឱវាទពីបុរាណកាល) | -//- | ១២ |
| ១០- | ទីអង្គុយ (ក្មេង) | -//- | ១៣ |
| ១១- | លក្ខណៈអង្គុយនៅមុខអ្នកធំ | -//- | ១៥ |
| ១២- | អង្គុយលើកៅអី | -//- | ១៨ |
| ១៣- | អង្គុយគោរពចំពោះស្ត្រី និងមនុស្សចាស់ | -//- | ១៩ |
| ១៤- | អង្គុយគោរពចំពោះព្រះសង្ឃ | -//- | ២០ |
| ១៥- | អង្គុយក្នុងរថ | -//- | ២១ |
| ១៦- | ឈរ (ឥរិយាបថទី៣) | -//- | ២២ |
| ១៧- | ឈរនៅទីប្រជុំ | -//- | ២៣ |
| ១៨- | ឈរជិតអ្នកអង្គុយ | -//- | ២៤ |
| ១៩- | ក្រោកឈរ | -//- | ២៥ |


www.facebook.com/7khmer
Fb page : Entertainment  And Knowledge

| | | |
|---|---|---|
| ២០- នៅកន្លែងធ្វើការ........................ | ទំព័រ | ២៥ |
| ២១- នៅទីផ្សារ........................ | -//- | ២៦ |
| ២២- ឈរលេង........................ | -//- | ២៧ |
| ២៣- ឈរគោរពទង់ជាតិ និងភ្លេងជាតិ................ | -//- | ២៧ |
| ២៤- ដើរ ( ឥរិយាបទទី ៤ )........................ | -//- | ២៨ |
| ២៥- ដើរក្នុងក្បួនហែ........................ | -//- | ២៩ |
| ២៦- ដើរជាមួយព្រះសង្ឃ........................ | -//- | ៣០ |
| ២៧- ដើរកាត់ហ្វូង........................ | -//- | ៣០ |
| ២៨- កិរិយាដើរ........................ | -//- | ៣១ |
| ២៩- ដំណើរដើរកន្លង........................ | -//- | ៣២ |
| ៣០- បង្វិលខ្លួន........................ | -//- | ៣៣ |
| ៣១- ក្អក-តណ្ហាស........................ | -//- | ៣៥ |
| ៣២- ខាក-ស្ដោះ........................ | -//- | ៣៥ |
| ៣៣- ស្វាប........................ | -//- | ៣៧ |
| ៣៤- បង្គំ សំពះ........................ | -//- | ៣៧ |
| ៣៥- សំពះសួរ-សំពះលា........................ | -//- | ៤១ |
| ៣៦- លក្ខណៈសំពះ........................ | ទំព័រ | ៤២ |
| ៣៧- កិរិយាដែលសំពះ........................ | -//- | ៤៣ |
| ៣៨- គំនាប់ងក់ក្បាលចាប់ដៃ........................ | -//- | ៤៣ |
| ៣៩- ប្រគេន-ថ្វាយ-ជូន........................ | -//- | ៤៦ |


www.facebook.com/7khmer
Fb page : Entertainment  And Knowledge

៤០- ហុច .............................. ទំព័រ ៤៧
៤១- របស់ប្រគេនលោកសង្ឃ-ថ្វាយក្សត្រិយ៍-ជូនបុព្វការីឬចៅហ្វាយនាយ ឬចាសលព្រឹទ្ធាចារ្យ .............. -//- ៤៨
៤២- និយាយ .............................. -//- ៥០
៤៣- របៀបនិយាយ .............................. -//- ៥២
៤៤- និយាយក្នុងទីប្រជុំ .............................. -//- ៥៦
៤៥- និយាយលេង .............................. -//- ៥៩
៤៦- និយាយខ្សឹប .............................. -//- ៦០
៤៧- ត្រូវនិយាយខ្សឹប .............................. -//- ៦០
៤៨- មិនត្រូវនិយាយខ្សឹប .............................. -//- ៦២
៤៩- មិនត្រូវនិយាយភាសាដទៃ .............................. -//- ៦៣
៥០- និយាយចំអកឡកឡឺយ .............................. -//- ៦៤
៥១- និយាយបន្ទោស-រំលឹកដាស់តឿន .............. -//- ៦៤
៥២- និយាយកុហក .............................. -//- ៦៦
៥៣- និយាយកាត់ .............................. -//- ៦៧
៥៤- និយាយនៅពេលបរិភោគអាហារ .............. -//- ៦៨

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## គារវកិច្ច

គារវកិច្ច ជាវិន័យមួយធំបំផុតសំរាប់មនុស្សទាំងសកលលោកទាំងមូល គ្រប់ជាតិ គ្រប់សាសន៍ត្រូវរៀនអោយចេះដឹង មិនអាចខ្វះខាតត្រង់ណាមួយឡើយ តាមទម្លាប់ទំនៀបប្រទេសរៀងៗខ្លួន និងទម្លាប់ទំនៀបបរទេសខ្លះទៀតផង សំរាប់ប្រើប្រាស់តាមកាលៈទេសៈ ព្រោះមានកាលខ្លះគារវកិច្ចនេះត្រូវប្រតិបត្តិតាមរបៀបស្រុកទេសយើង មានកាលខ្លះត្រូវធ្វើតាមរបៀបស្រុកទេសគេដែលយើងចូលទៅ ។

ឧបមាដូចអ្នកស្រុកក្នុងអាស៊ីទ្វីប នោះច្រើនអង្គុយរាបគឺអង្គុយលើកន្ទេល លើក្តារឬអង្គុយលើគ្រែផ្សេងៗ មានក្តារជឿជាដើម តែរបៀបអង្គុយខុសៗគ្នា ។ ខ្មែរ - សៀម - លាវ អង្គុយបត់ជើង ចិន - យួន អង្គុយពែនភ្នែន... តាមបុរាណកាល ។ ដល់មកសម័យអារ្យធម៌អឺរ៉ុបចូលមក របៀបនៃគារវកិច្ចបុរាណក៏ប្រែក្លាយខ្លះ បន្តិចម្តងៗរៀងមក តែពុំទាន់ពាល់រលុបទាំងអស់ទេ គ្រាន់តែកាត់ខ្មែរខ្លះ សៀមខ្លះ យួនខ្លះ លាវខ្លះ និងអឺរ៉ុបខ្លះ តាមអ្នកស្រុករាប់អាន ។

ដូច្នេះគារវកិច្ចកើតនៅក្នុងឥរិយាបទទាំង៤ ជាដើម ថែមវាចានិងកិរិយាផ្សេងៗខ្លះមកទៀត ដូចជាថ្វាយបង្គំ, សំពះ, ក្អក, កណ្ដាស, ខាក, ស្តោះ, សើច ។ល។

មិនបានតែទម្លាប់ទំនៀមរបស់បច្ចុប្បន្នលោកនេះទេ ធម្មចរិយាមានតាំងពីពុទ្ធកាលមក គឺពុទ្ធភាសិតក៏មាន បុរាណភាសិតក៏មាន ។

### ពុទ្ធភាសិតគឺ សប្បុរសធម៌ ៧ យ៉ាង :

១- ធម្មញ្ញុតា : ភាពជាអ្នកស្គាល់ហេតុនៃសេចក្តីសុខ និង ទុក្ខ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

២- អត្ថញ្ញុតា : ភាពជាអ្នកស្គាល់ផលគឺសុខនិងទុក្ខកើតអំពីហេតុ ។

៣- អត្តញ្ញុតា : ភាពជាអ្នកស្គាល់ខ្លួនថា "រាល់ថ្ងៃនេះយើងជាអ្នកប្រកបដោយ ជាតិ, យស, សក្តិ, សម្បត្តិ, បរិវារ, សេចក្តីចេះដឹង និង គុណធម៌ក្នុងខ្លួនត្រឹមណា ហើយប្រព្រឹត្តតាមគួរដល់ឋានៈរបស់ខ្លួន" ។

៤- មត្តញ្ញុតា : ភាពជាអ្នកស្គាល់ប្រមាណក្នុងការរកចិញ្ចឹមជីវិតដោយប្រពៃ និងការបរិភោគ ។

៥- កាលញ្ញុតា : ភាពជាអ្នកស្គាល់វេលាដែលគួរនឹងប្រកបកិច្ចការនោះ ។

៦- បរិសញ្ញុតា ភាពជាអ្នកស្គាល់ប្រជុំជន គឺត្រូវធ្វើកិរិយាយ៉ាងនេះៗ ត្រូវនិយាយយ៉ាងនេះៗ ឱ្យសមតាមលក្ខណៈប្រជុំនោះ ។

៧- បុគ្គលបរោបរញ្ញុតា : ភាពជាអ្នកស្គាល់បុគ្គល ថាអ្នកនេះល្អ អ្នកនេះអាក្រក់ គួរគប់រក ឬ មិនគួរគប់រក ។

## បុរាណភាសិត

ចាស់ៗលោកច្រើនប្រដៅកូនចៅ ដោយភាសិតផ្សេងៗ ដើម្បីដឹកនាំកូនចៅ ឱ្យស្គាល់ធម្មចរិយា ឱ្យស្គាល់សម្បត្តិមនុស្សល្អ ឱ្យចេះរក្សាពូជពង្សវង្សត្រកូល ឱ្យសមគួរតាមឋានៈ និងយសសក្តិគ្រប់ៗគ្នា ។

ដូចជា :

១- ចោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

២- ស្លឱ្យសាប អង្គុយឱ្យទាប ស្ដីឱ្យសុភាព បួកឱ្យខ្ពស់ ។

៣- ប្រពន្ធល្អ ច្រើនចាញ់ប្តី... ។ល។

៤- ពាក្យច្រើនភូតចាញ់រាជ្ញា.... ។ល។

៥- សំដីសរជាតិ មារយាទសរត្រកូល... ។ល។

៦- សិរសាទន់ទាប សុភាពឱនអង្គ... ។ល។

នឹងអធិប្បាយក្នុងឥរិយាបថទាំង ៤ ជាដើមគឺ ដេក. អង្គុយ. ឈរ. ដើរ ។

## ដំណេក

បុរាណកភាសិតប្រដៅថា "ដំណេកដេកជាខ្ពាត អោយសំអាតសំអាងជា ទើបទេព្តារក្សា ចំរើនសុខស្រីសួស្តី" ។

ពាក្យលោកទូន្មានយើងរាល់គ្នាឱ្យរៀបចំដំណេកឱ្យមានខ្ពាតគឺឱ្យមានទីកន្លែងដេកបិទបាំងឱ្យជាបន្ទប់ ដាច់ដោយឡែកអំពីកន្លែងទទួលភ្ញៀវ និងកន្លែងអាស្រ័យបាយទឹក ។ បើរៀបផ្ទះសំបែងអោយច្រឡំកន្លែងដំណេក និងកន្លែងទទួលភ្ញៀវ ឬកន្លែងអាស្រ័យបាយ នោះមិនរាប់ថាជាខ្ពាតនោះទេ ។

"ឱ្យសំអាតសំអាងជា" គឺឱ្យបោសប្រាសត្រវាសទីដំណេកឱ្យស្អាត នោះតើយ៉ាងណាមិញ? ត្រង់នេះគឺប្រកបគ្នានឹងតប្រាអនាម័យ ក្នុងសកលលោកទាំងមូល ។ ធម្មតាអ្នកស្អាតតែភ្ញាក់ឡើងពីដំណេកហើយរមែងពាក់មុង ឬរួតមុងឱ្យបានរៀបរយល្អរួចទើបរលាស់ភួយ. ផាហ៊ុំ បោសត្រវាសពូក រៀបចំកំរាលពូក. ខ្នើយកើយ. ខ្នើយឱប

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ្នើយជើង ឱ្យបានត្រឹមត្រង់ល្អឡើងវិញដូចកាលមុនពេលដេក យ៉ាងនេះតែរាប់ថ្ងៃឥតមានខាន ។ ម្លោះហើយលោកពោលថា "ទើបទេព្តារក្សា ចំរើនសុខស្រីសួស្តី" ថាទេព្តានឹងរក្សាថែទាំអ្នកដែលស្អាតនោះ ទាំងជួយចំរើននូវសេចក្តីសុខដល់អ្នកនោះទៀត នេះបើយើងគិត តាមភាសិតខាងលើនេះ ។ តែបើពិព្រោះតាមពម្រាររនាម័យវិញ ក៏បានសេចក្តីដូចគ្នា ។ ព្រោះថាបើយើងព្យាយាមសំអាតដំណេក មិនឱ្យធូលី. សម្រាម. ក្រឡាត ឬវត្ថុស្មោកគ្រោកមាននៅលើដំណេកយើង មេរោគក៏ពុំអាចបង្កើតជាជម្ងឺអ្វីមួយដល់រូបកាយយើងបានឡើយ ដូច្នេះហើយសុខគង់មានដល់យើងច្រើនជាងទុក្ខគឺថាពុំសូវមានរោគាពាធបៀតបៀនករជ្ជកាយឱ្យទន់ទាបទុព្វលភាពដុនដាបទៅរែរប់ពេក ។

# ឥរិយាបថទី ១

## ~ដេក~

កិរិយាដែលដេកនោះមានលក្ខណៈប្រពៃណាស់ តាមកាល តាមដំណើរ. តាមទំនង ។ តាមធម្មតាបើយើងចូលដំណេកត្រូវរៀបកន្ទេល. ពូក. ខ្នើយ ពោសសំអាតទីដំណេកឱ្យស្អាត ហើយបិទទ្វារបន្ទប់ឱ្យពត់មត់ ។

អ្នកទាំងឡាយមានធុរៈយ៉ាងណា ក៏មិនត្រូវប្រានបើកទ្វារបន្ទប់គេឯងឡើយ ។ បើមានកិច្ចជាអាសន្ន គប្បីស្រែកហៅ ឬក៏គោះទ្វារ ជញ្ជាំងហៅឱ្យចេញបេកនិយាយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

៨៦ ។ កុំគប្បីចូលទៅក្នុងបន្ទប់ដំណេកគេឱ្យសោះ បើគេពុំបានអញ្ជើញឱ្យទៅទេ ។

អ្នកដែលមានដំណេកល្អ ចេះប្រយ័ត្នខ្លួនដោយមិនបោះជើងបោះដៃច្រវេងច្រវាង ចេះប្រយ័ត្នសំពត់អាវ ចេះរៀបខ្លួនឱ្យស្រួលបួលមុននឹងលក់ស្កល់ទៅ ។

## ក្មេងត្រូវគោរពចាស់

មាតា, បិតា, គ្រូបាអាចារ្យចាស់ទុំ ដែលជាអ្នករក្សាព្យាបាលក្មេង ត្រូវបង្ហឹកបង្ហាញឱ្យចេះការវកិច្ចនេះ តាំងពីនៅតូច ដល់ចំរើនឡើងកូនចៅរបស់យើងនឹងចេះដឹងយកតម្រាប់តាម ។

មួយទៀត បើម្ដាយ-ឪពុក កំពុងអង្គុយលេង មិនត្រូវឱ្យកូនចៅដេកសំយ៉ុងជើងមកលើឡើយ ។

អ្នកដេកហើយតែពុំទាន់លក់ បើមានព្រះសង្ឃ, ក្សត្រ, មន្ត្រី, ចាស់ព្រឹទ្ធាចារ្យដើរមកជិតនោះត្រូវក្រោកអង្គុយ ឬអង្គុញជើងគួរសម ទើបជាចរិយាល្អមួយ ។ បើចាស់រាស្រ័យដំណេកនៅកន្លែងបួមក្មេងមិនត្រូវ ទៅដេកទន្ទឹមឬដេកសំយ៉ុងជើងលើចាស់នោះឱ្យសោះឡើយ ឬទៅធ្វើអ្វីជាការមិនគប្បី ជាដំណើរឱ្យរំខានដល់អ្នករាស្រ័យដំណេកនោះ ទាល់តែខានលក់ទៅ ។

គេអង្គុយរាល់គ្នាក្នុងទីប្រជុំ យើងមិនត្រូវទៅដេកជិតវង់អ្នកអង្គុយប្រជុំនោះឡើយ យើងមិនត្រូវយកកូនចៅទៅឱ្យដេកនៅទីនោះទៀត ។ បើកូនចៅងងុយដេកត្រូវតែនាំយកទៅផ្ទះ ( ត្រង់នេះមានអ្នកស្ដាប់ទេសន៍ជាដើមយកកូនចៅទៅឱ្យដេកជិត

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ្លួនខាងគេឯងរាល់គ្នា) ។

អ្នកដែលជាពុទ្ធមាមកៈ ពុទ្ធមាមកា តែងតែមានកន្លែងរៀបអសនៈធ្វើសក្ការបូជាមានព្រះបដិមករជាដើម នៅក្នុងផ្ទះសម្បែងក្នុងល្វែងណាមួយដោយ គួរសម ។ ដូច្នេះក្នុងកិច្ចគោរពមិនត្រូវអាស្រ័យដំណេកដេកសណ្តូកជើងត្រង់ទៅ ទីនោះឡើយ សូម្បីតែកូនចៅដែលមិនទាន់ដឹងក្តីក៏គប្បីទូន្មានអោយខ្លាចបាប ឱ្យចេះ គោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាដរាប ។

បើនឹងពោលឱ្យឧក្រិដ្ឋទៅទៀតថានៅក្នុងផ្ទះនីមួយៗ គប្បីកុំឱ្យកូនចៅដែលមានបន្ទប់ដំណេកផ្សេងពីមាតាបិតាទៅ ហើយដេកយកជើងទៅរកបន្ទប់មាតាបិតាឡើយ ។

មូលសេចក្តីទៅ ត្រូវចាំថា យើងត្រូវគោរពបុគ្គលទាំងឡាយដែលគួរគោរព យើងមិនត្រូវដេកសណ្តូកជើងទៅត្រង់បុគ្គលនោះៗទៅត្រង់ទីនោះៗជាដាច់ខាត ។

(ត្រង់អធិប្បាយចេញថា "ក្មេង" ថា "ចាស់" នោះត្រូវលើកយកអ្នកមានបណ្តាសក្តិធំ និង សក្តិតូច និងរាស្ត្រសាមញ្ញ មកប្រៀបផ្ទឹមផង ជាគោលចរិក ក្នុងកិច្ចគោរព និងសេចក្តីគួរសមកាន់គ្នានឹងគ្នា ។



www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ឥរិយាបថទី ២

## ~អង្គុយ~

អង្គុយបានច្រើនជាន់ ច្រើនថ្នាក់ ។ បើរៀបតាមបែបយ៉ាងនោះមានតែពីរយ៉ាង គឺអង្គុយរាប និងអង្គុយកៅអី ។ បែបទាំងពីរយ៉ាងនេះត្រូវចាត់តាមជាន់តាមថ្នាក់ជាដរាប មិនត្រូវឱ្យភ្លាត់បាន ហើយឱ្យសមតាមពេលតាមពិធីនោះ១ផង ។ អ្នករៀបកន្លែងជាបច្ច័យនឹងអ្នកអង្គុយ ។ ហេតុដូចម្តេច ?

ថាអ្នករៀបកន្លែងត្រូវចេះរៀប ឯអ្នកអង្គុយត្រូវស្តាប់អ្នកជូនកន្លែងគឺជាភ្ញៀវ ត្រូវទទួលកន្លែងដែលគេអញ្ជើញឱ្យអង្គុយ បើភ្ញៀវចេះតែជជែកប្រកែកមិនព្រមទទួលតាមគេអញ្ជើញឱ្យអង្គុយ នោះរបៀបដែលអ្នកចាត់ការប្រុងប្រៀបទុករមែងតែនឹងខូចអស់ ម្លោះហើយពិធីដែលធ្វើនេះក៏ពុំបានរៀបរយល្អ ។

មួយសោតឯអ្នករៀបកន្លែងរៀបភ្ញៀវទៀត ត្រូវឱ្យដឹងឋានៈនៃភ្ញៀវ តែលើកតែពេកឬដាក់តែពេក គេកើតទោមនស្ស គេពុំអាចទទួលកន្លែងនោះបាន ។

## ទីអង្គុយជាផ្លូវការ

## (ព្រះសង្ឃ)

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក្នុងពិធីនីមួយៗ ដែលជាព្រះរាជពិធីក្តី ជាពិធីនៃរដ្ឋាភិបាលក្តី មិនថាពិធីធំឬតូចឡើយ នោះបណ្តាព្រះសង្ឃដែលមានសមណសក្តិជាទីរាជាគណៈ និងឋានានុក្រម នាម៉ឺនសព្វមុខមន្ត្រីធំ-តូច ត្រូវមានទីបង្គុយតាមយសសក្តិ ។

ចំណែកសមណសក្តិ ព្រះសង្ឃត្រូវគង់តាមលំដាប់សក្តិ ដែលព្រះមហាក្សត្រត្រតាំងប្រគេន នោះតាមរបៀបតពីព្រះសង្ឃនាយកមក ត្រូវព្រះរាជាគណៈ ទី១ ទី២ ទី៣ ទី៤ ព្រះគ្រូ - បាឡាត់ - សមុហ៍ - បៃដីកា ។

សមណសក្តិនេះ មានផ្ចិតសំរាប់សំគាល់ឋានៈ ។ ចុះបើព្រះរាជាគណៈ ទី១ និងទី១ ទី២ និងទី២ ... ។ល។ មកជួបគ្នានោះត្រូវគង់តាមចំនួនវស្សាចាស់ខ្ចី នៃយសសក្តិ មិនមែនរាប់យកតាមចំនួនវស្សាផ្នួសទេ ឬ ចំនួនឆ្នាំជន្មាយុទេ ។

បើជាក្រៅពីផ្លូវការវិញ ទៅទីប្រជុំជនក្នុងភូមិ ឬតាមគេហដ្ឋាន ឧបាសកឧបាសិកានោះយើងគប្បីចូលចិត្តអោយបានថា គណសង្ឃដែលយើងនិមន្តលោកមកនោះ លោកគង់តាមលំដាប់វស្សាចាស់-ខ្ចី មិនមែនគិតតាមព្រះជន្មលោកទេ ពីតាមបញ្ញត្តិក្នុងវិន័យដែលព្រះពុទ្ធអង្គទ្រង់ត្រាស់បញ្ញត្តិទុកមក ។

មិនតែប៉ុណ្ណោះទេ ត្រូវយើងរៀបសេនាសនៈថ្វាយព្រះសង្ឃឱ្យខ្ពស់ជាងគ្រហស្ថដរាប គឺថាយ៉ាងទាបណាស់ត្រឹមកន្ទេលពីរជាន់ ឬ កន្ទេល១ជាន់ ព្រំចៀម១ជាន់ ។ យើងជាគ្រហស្ថត្រឹមកន្ទេល១ជាន់បានហើយ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# គ្រួហស្ថ-ក្នុងព្រះទីន័ងទេវាវិនិច្ឆ័យ

នៅក្នុងព្រះបរមរាជវាំង កាលមានព្រះរាជពិធីទ្វាទមាសម្តង១ ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងស្តេចយាងចេញជាព្រះរាជាធិបតី នោះបណ្តាភ្នាក់ងារត្រូវរៀបទីព្រះទីន័ងថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាខាងដើម - ខាងមុខបង្អស់ បន្ទាប់មកថ្វាយព្រះរាជវង្សានុវង្សក្សត្រាជាទី ២. គណៈរដ្ឋមន្ត្រីទី ៣. មន្ត្រីសក្តិ១០ហ៊ូពាន់ទី ៤. (ឧត្តមមន្ត្រីធុំតលេខ. ចាងហ្វាងសាលាវិនិច្ឆ័យ) តទៅវរមន្ត្រី. អនុមន្ត្រី. ក្រមការ... ។ល។ យ៉ាងនេះជារបៀប ជាទម្លាប់-ទំនៀម ។

ព្រះរាជវង្សានុវង្សក្សត្រាដែលឡើងគាល់ត្រូវគង់ជាមួយគ្នាទាំងអស់នៅកន្លែងមួយ ដែលមុខងារបានចាត់ទុកថ្វាយ ។ ការគង់នេះត្រូវជ្រាបថាព្រះអង្គគង់តាមថ្នាក់សក្តិយសធំ-តូចជាលំដាប់ ។

ចំណែកខ្ញុំរាជការដែលគាល់បំរើព្រះអង្គព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នោះត្រូវមានកន្លែងអង្គុយគាល់ដោយឡែក ដែលក្រុមព្រះរាជមន្ទីររៀបចំបំរុងទុកជារបៀបស្រេច១ ។ ដូច្នេះព្រះរាជវង្សានុវង្សក្តី របស់លោកមន្ត្រីធំ-តូចក្តី ត្រូវទទួលយកទីបង្គុយដែលចាងហ្វាងព្រះរាជបន្ទីរ បានអញ្ជើញស្តេចគង់-អញ្ជើញអង្គុយ ទើបមានរបៀបរៀបរយល្អ តាមច្បាប់តាមទំនៀម ។

ខាងស្ត្រីវិញក៏មានរបៀបប្រហែលៗគ្នាជាទម្លាប់ទំនៀម ។

នាក្រោយព្រះមហាស្វេតច្ឆត្រជាកន្លែងសម្រាប់ស្ត្រីគាល់ព្រះមហាក្សត្រាធិបតីគ្រប់ព្រះរាជពិធីទ្វាទសមាស ។ នោះនៅចំពីក្រោយព្រះមហាស្វេតច្ឆត្រ ត្រូវចាត់ជា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

៣របៈ ទី១ សម្រាប់ថ្វាយសម្ដេចព្រះជននីនាថ. សម្ដេចព្រះមាតុច្ឆា. សម្ដេច-ព្រះបិតុច្ឆា ។ល។ ទី២បន្ទាប់តទៅខាងក្រោយ ក្សត្រីទីព្រះអង្គម្ចាស់និងអ្នកអង្គម្ចាស់ ទី៣ ខាងក្រោយបង្អស់ ចៅជិត. ចៅចម (អស់អ្នក) ។

នាខាងស្ដាំទីទាំង៣ នេះក្នុងល្វែងដោយខ្លួនសំរាប់ចំទាវខុនណាង (គឺភរិយាមន្ត្រីធំ-តូច) នោះក៏មានរបៀបតាមឋានន្តរសក្តិនៃស្វាមីទាំងអស់ ។

ដែលលើកយករបៀបទីគង់ក្សព្របានព្រះករុណាជាម្ចាស់ជីវិតលើត្បូងជាប្រធានជរាបចុះមកព្រះរាជវង្សានុវង្សជាល័ដាប់ទាំងក្សត្រក្សត្រា ទាំងនាម៉ឺនសព្វមុខ-មន្ត្រីកវីបណ្ឌិត ចៅជិតចៅចម ចំទាវខុនណាង មកជាគូយ៉ាង ដើម្បីជាបែបផែនពន្យល់បំភ្លឺរបៀបរៀបទីសេនាសនៈ ទទួលភ្ញៀវឱ្យបានសមរម្យកុំឱ្យខុសឆ្គងពេក ។

បើយើងយល់របៀបនេះបានហើយ កាលគ្រាយើងមានកិច្ចធុរៈបុណ្យទានឬរៀបពិធីមង្គលការផ្សេងៗ មានអញ្ជើញស្ដេចក្សត្រិយ៍ខត្តិយវង្ស នាម៉ឺនធំ-តូចព្រៀងលាន ញាតិសាច់សាលោហិត និងមិត្រភក្តិមកជាអធិករធម នោះគប្បីចាត់ទីកន្លែងឱ្យសមតាមយសសក្តិជាដរាប ។

នេះចំណែកខាងក្សត្រិយ៍ និងមន្ត្រី ក៏ល្មមចូលចិត្តបាន ។

ចំណែករាស្ត្រសាមញ្ញគឺអ្នកឥតបណ្ដាសក្តិនោះ គេត្រូវរាប់យកចាស់ព្រឹទ្ធាចារ្យជាធំក្នុងទីប្រជុំនីមួយៗ ។ ប្រៀបដូចយើងធ្វើបុណ្យនិមន្តព្រះសង្ឃចំរើនព្រះបរិត្តនៅផ្ទះយើងឬនៅវត្ត នោះគេដាក់លោកអាចារ្យ (គឺអ្នកនាំថ្វាយបង្គំព្រះសូមសីល... ។ល។) ឱ្យអង្គុយមុខបង្អស់នៅកណ្ដាលទីប្រជុំ បន្ទាប់តៗមកក្រោយ

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

គេអញ្ជើញលោកចាស់ៗ ឡើងទៅជិតលោកអាចារ្យ ទើបក្មេងៗជាលំដាប់ចុះមក ។ តែបើមាននាម៉ឺន ធំ តូច អញ្ជើញមកខ្លះផង គប្បីអញ្ជើញអស់លោកទាំងនោះអង្គុយជិតស្មើជួរនឹងលោកអាចារ្យទើបសម ។ ស្ត្រីនិងបុរសក៏ត្រូវញែកជាពួកនៅក្នុងទីនោះ គឺតាមប្រវេណីខ្មែរពីបុរាណមក ការប្រជុំធ្វើបុណ្យឬធ្វើពិធីអ្វីនីមួយៗ គេតែងតែផ្តុំស្រីដោយស្រី ប្រុសដោយប្រុស ថ្វីបើប្តីប្រពន្ធមកពីផ្ទះជាមួយគ្នា តែដល់ទៅទីប្រជុំគេតែងតែបែកគ្នាទៅរកទីកន្លែងតាមស្រីតាមប្រុសជាធម្មតា ។ នៅគេហស្ថានរបៀបរៀបភ្ញៀវនេះស្រេចហើយនៅលើម្ចាស់បុណ្យឬអ្នកចាត់ការ ។ នៅទីវត្តវិញស្រេចហើយតែលោកអាចារ្យ ជាប្រមុខចាត់ចែងធ្វើកាលទានឬបុណ្យទ្វាទសមាសដែលលោកអាចារ្យមានស្នាកឬកម្មវិធី ចែកចាយផ្សាយដំណឹងអញ្ជើញទាយកទាយិកាជើងវត្តមក ។

## តាមអារ្យធម៌អឺរ៉ុប

បណ្តាអារ្យជននៅប្រទេសអឺរ៉ុបដែលទៅកាន់ទីប្រជុំនីមួយៗ តាមសេចក្តីអញ្ជើញរបស់សមាគមណាមួយ ឬ របស់ឥស្សរជនណាមួយ ដូចជាទៅស្តាប់សន្និសិទ ឬ បាឋកថា ... ។ល។ នោះគេរាប់អានអង្គុយទន្ទឹមគ្នាប្តីប្រពន្ធ ១ ។

ទាំងទៅមើលល្ខោនល្បាំក៏ច្រៀងនិងល្ខោនផ្សេងៗ... លោកអ្នកដែលអញ្ជើញ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទៅក៏តែងតែអង្គុយជាគូៗភរិយាស្វាមីជាដរាប ជូនកាលមានទាំងកូនស្រីប្រុសទៅជាមួយផង នោះគេអង្គុយតាមជួរតាមក្រុមគ្រួសារទៅបានជាទម្លាប់ ។

## តាមឱវាទពីបុរាណកាល

ចាស់ៗច្រើនទូន្មានកូនចៅថា " ត្រូវអង្គុយឱ្យទាប " តើយ៉ាងហោចម៉ិញ? ។ ក្នុងពេលប្រជុំម្តងៗ រមែងមានជនគ្រប់ជាន់គ្រប់ថ្នាក់ក្សត្រិយ៍, មន្ត្រី, រាស្ត្រសាបញ្ញាប្រុសស្រី ចាស់ក្មេងជាធម្មតា, ហើយលោកអោយឱវាទយើងទាំងអស់គ្នា ឱ្យអង្គុយឱ្យទាប ។ ចុះទីត្រង់ណាដែលយើងសំគាល់ទុកថាជាទីទាប ? ។

យើងរាល់គ្នាត្រូវឱ្យដឹងឋានៈរបស់យើង យើងអាចស្គាល់បាន ចូលចិត្តបានថាក្នុងប្រជុំនេះ (មិននិយាយពីប្រជុំជាផ្លូវការទេ) គឺអ្នកស្រុកភូមិផងល្បងជាមួយញាតិសាច់និងមិត្រភក្តិ... ។ល។, ដូច្នេះយើងអង្គុយត្រង់នេះ ជាទីគួរសម តែយើងកុំគប្បីទៅអង្គុយដល់ទីនោះភ្លាមទេ យើងគប្បីរើសយកទីបន្ទាប់ពីនោះបន្តិចមក យ៉ាងនេះហើយហៅថាអង្គុយឱ្យទាប ព្រោះយើងបារម្ភក្រែងហានអ្នកធំជាងយើង ឬ ចាស់ជាងយើង អញ្ជើញមកទៀតមិនរវល់នឹងរើកន្លែង ។

មួយវិញទៀត ក្នុងពេលប្រជុំនោះ បើមានមន្ត្រីចាស់ (រ៉ូវត្រេត) ដែលលោកមានយសសក្តិធំខ្ពស់ដែរ ឬមានចាស់ព្រឹទ្ធាចារ្យ ដែលប្រកបដោយលក្ខណៈ ជាអ្នកស្រគត់ស្រគំ អ្នកសមាទានរក្សាសីល សមរម្យជាទីគោរពរបស់យើង ទុកដូចជាឪពុកយើង-ម្តាយយើង-ជីដូន-ជីតាយើង យើងគប្បីអញ្ជើញអោយខិតឡើងទៅមុខបន្តិច

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក៏គួរដែរ ទុកណាកជាយើងជាមន្ត្រីធំក្តី តូចក្តី ដែលនៅងារពេញទី ។ ចំណែកខាងស្រី១ ក៏គប្បីប្រើរបៀបអង្គុយដូចអធិប្បាយហើយខាងលើនេះ ។

របៀបអង្គុយនឹងឱ្យរៀបរយបានល្អអាស្រ័យភ្ញៀវ និងការគួរសមឱ្យបរិបូណ៌ផង បើភ្ញៀវឥតល្បបមិនគិតក្រែងបានការរំខានដល់ភ្ញៀវនិងភ្ញៀវផងគ្នា ឬដល់អ្នកម្ចាស់ផ្ទះ ម្ចាស់បុណ្យ នោះជាអំពើអោយកើតឡើងនូវសេចក្តីមិនស្រួលក្នុងទីប្រជុំ ឬបង្កើតនូវសេចក្តីចង្អៀតចង្អល់ចិត្តគេឯងរាល់គ្នា ។

## ~~~ក្មេង~~~

ក្នុងទីប្រជុំនីមួយ១ ត្រូវប្រយ័ត្នក្មេង១ដែលឥតល្បបកុំឱ្យចូលទៅដណ្តើមកន្លែងដែលចាស់១រង្គុយ ។ មានក្មេងខ្លះអង្គុយហើយមិននៅស្ងៀមទៀតផងចេះតែក្រោកដើរចេញចូលកន្លងដៃជើងចាស់ទុំឥតកោតញញើត ។ ក្មេងខ្លះមិនព្រមអង្គុយរាបនឹងកន្ទេលទេ ទារអង្គុយលើភ្លៅម្តាយឬជីដូន ខ្លះក៏បានអង្គុយលើភ្លៅម្តាយហើយមានការចាប់ពោចរោចសំពត់អាវម្តាយ ឬទារយកនេះយកនោះទៀត ។

ចំណែកខាងអ្នកអង្គុយកៅអីក៏ដូចគ្នា មានលោកអ្នកខ្លះយកកូនចៅទៅផងហើយយកទៅឱ្យអង្គុយកៅអី១ ។ បើយ៉ាងនេះភ្ញៀវម្នាក់មានក្មេងម្នាក់ទៅផងនោះអ្នកផ្ទះរកកៅអី និងទីកន្លែងជូនភ្ញៀវពុំគ្រប់គ្រាន់ទេ ។ មានកាលមិនមែនកូន-

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចៅរបស់ភ្ញៀវទេ គឺកូនចៅរបស់អ្នកផ្ទះ បណ្តោយឱ្យមកដណ្តើមកន្លែងភ្ញៀវ១ពុំដឹងធ្វើដូចម្តេចក៏ស៊ូតែឈរទៅ ចំណែកភ្ញៀវអង្គុយរាបក៏ស៊ូទ្រាំចង្អៀតទៅ ។

ហេតុដែលនាំឱ្យខូចរបៀបអង្គុយយ៉ាងនេះ យើងអាចនឹងកែរួចស្រួលឡើងវិញបាន គឺថាយើងជាភ្ញៀវមិនត្រូវឱ្យកូនចៅទៅផងទេ ព្រោះគេអញ្ជើញតែត្រឹមយើង គេពុំបានអញ្ជើញកូនចៅយើងទេ ។ ចំណែកអ្នកផ្ទះត្រូវដឹងខ្លួនឱ្យច្បាស់ថា អញពុំបានអញ្ជើញកូនចៅគេទេ ដូច្នេះត្រូវកុំបណ្តោយឱ្យចៅអញទៅរំខានភ្ញៀវ ។

ចុះបើទៅប្រជុំនៅនាវត្តអារាម នោះទម្លាប់ខ្មែរគេតែងតែយកកូនចៅទៅផង ដើម្បីឱ្យកូនចៅចេះចង់ធ្វើបុណ្យទានទម្លាប់ឱ្យស្គាល់ ឱ្យស្រឡាញ់ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលជាទីពឹងរបស់ខ្លួន ជាពុទ្ធមាមកជន ។ ការដែលមានកូនចៅទៅវត្តជាកិច្ចប្រសើរក្រៃកែ តែបើនាំយកទៅហើយបណ្តោយឱ្យឥតល្បប ក៏ត្រឡប់ជាមិនប្រសើរវិញ ។

ពេលប្រជុំយ៉ាងសំខាន់ ដែលមិនត្រូវយកកូនចៅទៅជាមួយផងឱ្យសោះ ។ ត្រង់នេះយើងរាល់គ្នាគប្បីចូលចិត្តបានថា ប្រជុំណាមួយដែលគេតែងតែរាប់ចំនួនភ្ញៀវឱ្យមានកំណត់ថា មានប៉ុណ្ណេះប៉ុណ្ណោះ ។ ភ្ញៀវត្រូវប្រតិបត្តិតាមសំបុត្រអញ្ជើញ នោះយ៉ាងណាមិញ ? ថាបើអញ្ជើញតែស្វាមី ភរិយាកុំគប្បីទៅផងទេ ។ បើគេអញ្ជើញទាំងស្វាមីភរិយា នោះកុំគប្បីយកកូនចៅទៅផងឡើយ ។ បើគេអញ្ជើញគ្រួសារទាំងមូលទើបទៅទាំងរស់គ្នាបាន ។ ចុះដោយហេតុដូចម្តេច ?

នឹងលើកឧទាហរណ៍មួយជាតួយ៉ាង មកអធិប្បាយពន្យល់ជូនឱ្យឃើញការទាស់ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ប្រៀបដូចក្នុងពិធីរៀបអាពាហ៍ពិពាហ៍ គេតែងលៀងភ្ញៀវជាកិត្តិយសដោយមេត្រីភាពរវាងមិត្រភក្តិនិងសាច់សន្តាន ។ អ្នកដើមការតែងតែគិតចំនួនភ្ញៀវចំនួនកៅអី ចំនួនតុ ឱ្យត្រូវគ្នាកុំឱ្យមានខ្វះខាត ខ្លាចក្រែងភ្ញៀវរង់ចាំ ។ បើប្រសិនជាសល់តុវិញនោះពុំជាការអ្វីឡើយ ។ ត្រង់នេះហើយជាហេតុចង្អុលឱ្យយើងជាភ្ញៀវកុំគប្បីយកកូនចៅទៅផង ដែលអ្នកដើមការពុំបានគិតទីកន្លែងនិងម្ហូបចំណីទុកឱ្យ ។ មិនទាស់តែប៉ុណ្ណោះទេ ត្រូវដឹងថា គេតែងកំណត់ទុក រៀបទុកជាមុនឱ្យឃើញថាក្នុង ១ តុ ត្រូវដាក់ភ្ញៀវ ៦ នាក់ ឬ ៨ នាក់..... ។ ចុះបើភ្ញៀវណាមួយមានកូនម្នាក់យកទៅផង ហើយនិយាយសុំកៅអី ១ ទៀត ចានកាយ ១ ទៀត សមស្លាបព្រា ១ សំរាប់ទៀត តើឱ្យគេទៅរកឯណាមកឱ្យយើង ? នេះហើយជាហេតុដែលយើងធ្វើឱ្យគេរំខានឱ្យខូចរបៀបរៀបរយរបស់គេ ។ យើងគប្បីគោរពរបៀបគេឱ្យបានបរិបូណ៌ ។

ដូចប្រជុំមើលល្បែងរបាំផ្សេងៗក្តី ប្រជុំស្តាប់សន្និសិទក្តី.....។ល។ ដែលជាប្រជុំមានកំណត់ទីអង្គុយតាមចំនួនភ្ញៀវ នោះភ្ញៀវមិនត្រូវដឹកនាំយកអ្នកដទៃទៅផងទេ ឱ្យលើសពីសំបុត្រអញ្ជើញរបស់គេ ។

## ~~~លក្ខណៈអង្គុយនៅមុខអ្នកធំ~~~

ពាក្យថាអ្នកធំមួយម៉ាត់នេះ សំដៅយកព្រះសង្ឃ, ក្សត្រិយ៍, មន្ត្រី, ចៅហ្វាយនាយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គ្រូអាចារ្យ. មាតាបិតា.....។ល។ ចំពោះព្រះមហាក្សត្រិយ៍ នឹងក្សត្រិយ៍តាំងក្រុមនោះបើបណ្ដាសាមញ្ញជនជាពលរដ្ឋ ត្រូវការគាល់ថ្វាយសេចក្ដីផ្សេងៗក្ដី ឬ បានទទួលព្រះរាជឱង្ការពីម្ចាស់ផែនដីក្ដី ព្រះបន្ទូលក្សត្រិយ៍តាំងក្រុមក្ដី ត្រូវចូលទៅជិតហើយថ្វាយបង្គំ រួចអង្គុយឱ្យរាបទាបល្មមសមថ្វាយសេចក្ដីតាមហេតុរឿង ‹ នៅលើព្រះមហាប្រាសាទ ឬលើដំណាក់› ។ បើប្រសិនជានៅទីសួនឧទ្យាន ក៏ត្រូវអង្គុយលើចុងជើងទាំងពីរ ‹ ស្ទើរតែច្រហោង› កែងដៃទាំងពីរសង្កត់លើភ្លៅលើកចុងដៃឡើងផ្គុំថ្វាយបង្គំឱនក្បាលបន្តិច រួចទើបថ្វាយសេចក្ដីតាមដំណើរ ។ យើងជាពលរដ្ឋ មិនត្រូវស្រែកថ្វាយសេចក្ដីពីចម្ងាយឱ្យសោះជាដាច់ខាត ត្រូវរត់ចូលទៅជិត អង្គុយថ្វាយបង្គំសិនសឹមថ្វាយសេចក្ដីតាមការ ។

មន្ត្រីក្ដី អាណាប្រជារាស្ត្រក្ដី កាលចូលគាល់ព្រះរាជា ហើយទ្រង់ព្រះរាជទានព្រំ ឬ កន្ទេលជាទីអង្គុយ យើងត្រូវអង្គុយបត់ជើង កែងដៃទាំងពីរសង្កត់លើភ្លៅដៃប្រណម្យ ឱនក្បាលបន្តិច ហៅថា អង្គុយម៉ប ទើបសមរម្យ ។

លក្ខណៈអង្គុយនៅមុខអ្នកធំ គឺនៅចំពោះព្រះភក្ត្រព្រះមហាក្សត្រិយ៍ ជាដើមតទៅមន្ត្រី នឹងបុព្វការីជន ត្រូវអង្គុយឱ្យរាបរយជាដរាប ។

មិនត្រូវអង្គុយច្រហោង គងជើងពែនភ្នែនបញ្ឈរជង្គង់ឱ្យសោះ ព្រោះជាវិរំពើទាស់នឹងច្បាប់សំរាប់ស្រុកដែលមានទម្លាប់ទំនៀម ប្រើឱ្យគោរពប្រតិបត្តិ ក្សត្រិយ៍មន្ត្រី នឹងបុព្វការី ។

ត្រូវអង្គុយបត់ជើង ហើយកុំច្រត់ដៃចំហៀងខ្លួនក្ដី ទៅមុខក្ដី ទៅក្រោយក្ដី ជាដាច់ខាត ។ ចុះដៃទាំងពីរត្រូវទុកដាក់ទៅត្រង់ណា? ត្រូវផ្គុំគ្នាដាក់លើភ្លៅនៃជើងដែល

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

យើងបត់ពីលើ ។

បើរួយរបង្គុយត្រូវប្រែជើងបត់ទៅម្ខាងនោះមានបែបយ៉ាងឱ្យប្រែឱ្យល្អមើលទៀត មិនឱ្យឆ្គង មិនឱ្យឃើញច្រងេងច្រងាង ។ នោះត្រូវឱនខ្លួនទៅមុខកែងដៃទាំងពីរសង្កត់ ទៅលើភ្លៅ បង្ហើបអង្គុយបន្តិចឡើង ទើបដោះជើងត្រឡប់ទៅម្ខាងបានស្រួលហើយ រៀបរង្គុយជាថ្មី ។

របៀបប្រែរង្គុយផ្លាស់ជើងនេះ មិនត្រូវផ្លាស់ពីខាងមុខទេ ។ គេសំគាល់ថាបើនរណាប្រែអង្គុយផ្លាស់ជើងពីខាងមុខ អ្នកនោះជាមនុស្សមិនដឹងខុសត្រូវមិនចេះគួរសម មិនចេះគារវកិច្ច ឬ ពេចាត់ឱ្យឈ្មោះថាជាមនុស្សព្រហើន ។

ដែលលើកយករបៀបអង្គុយរាបគាល់ព្រះបបាក្សត្រិយ៍ មកអធិប្បាយជូនជាតួយ៉ាងដូចមានខាងលើនេះ ក៏ប៉ុន្តែត្រូវកែបន្តិចតទៅទៀត សំរាប់អង្គុយ នៅចំពោះព្រះសង្ឃ - មន្ត្រីធំ - តូច នាយចៅហ្វាយ និង បុព្វការី ។

បើយើងអង្គុយរាបនៅចំពោះព្រះភក្ត្រស្ដេចសង្ឃ ដែលព្រះមហាក្សត្រិយ៍លើកតំកើងឡើងឱ្យបានព្រះជាតិជាស្ដេច ដូចសម្ដេចព្រះសង្ឃរាជ ( ទៀង ) និងសម្ដេចព្រះសុគន្ធាធិបតី ( ប៉ាន ) នោះលក្ខណៈអង្គុយគាល់ក៏ត្រូវប្រើបែបអង្គុយគាល់ព្រះបហាក្សត្រិយ៍ដែរ ។ សូម្បីតែពាក្យស័ព្ទក៏ត្រូវប្រើពាក្យក្នុងព្រះរាជសព្ទទាំងរស់ ។

បើអង្គុយនៅចំពោះព្រះសង្ឃក្ដី - បន្ត្រីធំ - តូចក្ដី - នាយចៅហ្វាយក្ដី - បុព្វការីក្ដី ត្រូវប្រើលក្ខណៈឱ្យបានរៀបរយទាំងជើង - ដៃ ទាំងផ្លាស់ជើង - ផ្លាស់ដៃ ប៉ុន្តែមិនត្រូវម៉បដូចអង្គុយគាល់ព្រះមហាក្សត្រិយ៍និងក្សត្រិយ៍តាំងក្រុមទេ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

អង្គុយត្រង់ខ្លួនបានហើយ ។

## -អង្គុយលើកៅអី-

តាមរបៀបអឺរ៉ុប អង្គុយលើកៅអីហើយគងជើងឬក្រពាត់ជើងក៏រាប់ទុកជាកិច្ចគោរព ១ ដ៏គួរសមល្អមិនរើសមុខថាធំថាតូចថាស្រីថាប្រុសថាចាស់ថាក្មេងទេ ។ មិនតែប៉ុណ្ណោះកិច្ចគោរពគួរសមយ៉ាងធំគេរៀបស្ត្រីឆ្លាស់គ្នានឹងបុរសទៀតផង ដើម្បីបង្ហាញសេចក្តីលើកតំកើងយ៉ាងស្និទ្ធស្នាល ។

តាមទម្លាប់ទំនៀមខ្មែរក៏រាប់អានកៅអីជាទីរអង្គុយរបៀប១បែនពិតដែរ តែគារវកិច្ចចំពោះអ្នកធំនឹងស្រីនៅប្រកាន់ ពុំទាន់ឃ្លាតចាកទម្លាប់ទំនៀមចាស់នៅឡើយទេ ។ មិនត្រូវអង្គុយគងជើងព័ទ្ធជើងទេ និងរៀបររៀបអង្គុយគាល់ព្រះមហាក្សត្រិយ៍បន្តិចជាគំរូជូន ។

១- បើយើងឡើងក្រាបបង្គំគាល់ផ្ទាល់ព្រះមហាក្សត្រិយ៍ហើយព្រះរាជទ្រង់ព្រះមេត្តាបដិសណ្ឋារៈ ទទួលដោយព្រះរាជទានកៅអីអង្គុយនោះ តាំងពីក្សត្រិយ៍ថ្នាក់ដែលទាបចុះមកក្តី នាម៉ឺនសព្វមុខមន្ត្រីករីបពៀតក្តី ត្រូវលត់ជង្គង់ថ្វាយបង្គំ ឬបន្ទន់ខ្លួនថ្វាយបង្គំទទួល សឹមឡើងអង្គុយ ។

អង្គុយហើយត្រូវរៀបចំខ្លួនឱ្យសមរម្យ គឺដាក់ជើងទាំងពីរឱ្យរួមជិតទីមគ្នា (កុំយះកន្ធែក) ដៃទាំងពីរប្រណម្យដាក់លើភ្លៅ ឱនក្បាលបន្តិចចុះ សឹមថ្វាយសេចក្តី

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ផ្សេងៗ ។

២- បើឡើងក្រាបបង្គំគាល់ជាផ្លូវការ ដូចជាក្នុងព្រះរាជពិធីផ្សេងៗ ក្នុងព្រះទីន័ងទេវាវិនិច្ឆ័យ ដោយប្រោសព្រះរាជទានកៅអីអង្គុយដែរនោះរបៀបក៏ស្រដៀងៗគ្នា គឺថាជើងទាំងពីរត្រូវតែរៀបឱ្យស្រួល មិនត្រូវសណ្ដូកទៅមុខខ្លួនឱ្យត្រង់ មិនត្រូវផ្ដេកទ្រេតទៅក្រោយ ។ បើជាពិធីចំរើនព្រះបរិត្ត ដៃទាំងពីរត្រូវសំពះលោក មិនត្រូវលើកដៃទៅពាក់លើខ្នងកៅអី ។ យ៉ាងនេះទើបសមរម្យជាអ្នកគោរពប្រណិប័តន៍ព្រះបរមរាជ្យព្រិយ៍ តាមបែបផែនប្រវេណីរបស់ត្រកូលខេមរជាតិ ។

ប្រមូលសេចក្ដីទាំងរស់ឡើងអំពីលក្ខណៈអង្គុយរាបក្ដី កៅអីក្ដី ត្រូវរៀបចំខ្លួនប្រាណឱ្យបានស្រួលបួលកុំច្រខែងច្រខោងច្រងេងច្រងាង...... ត្រូវដាក់ជើងដាក់ដៃឱ្យស្រួលឱ្យសមតាមសុភាពជាអ្នកមានត្រកូល - មានពូជពង្សថ្លៃថ្នូរ ។

## ~គោរពចំពោះស្ត្រីនិងមនុស្សចាស់~

ក្នុងសាកលលោកទាំងមូល ធម្មជាតិបុរសរមែងបំពេញគារវកិច្ចឱ្យបរិបូរណ៍ចំពោះស្ត្រី ។ ទៅតាមរថឈ្នួល ដូចជារថភ្លើង រថយន្ត រថត្រាំវ៉ៃ...។ល។ តាមកប៉ាល់ធំ-តូច - ទូកចំលង... ។ល។ នៅទីប្រជុំទាំងឡាយទាំងពួង លើកតែរង្គុយដែលបង់លេខទិញដាច់ថ្លៃក្នុងពេលនោះៗ (ដូចមើលកុន-ល្ខោន) ។ បើមានស្ត្រីមកដល់ក្រោយហើយរកកន្លែងអង្គុយគ្មាន នោះបុរសដែលក្មេងជាងគេ ត្រូវគោរពស្ត្រីសំដែងសេចក្ដី

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គួរសមក្រោកឈរឡើង បន្ទឹទូវវាចារផ្អែមពិសាអញ្ជើញស្ត្រីនោះឱ្យអង្គុយយកកន្លែងខ្លួនថា "សូមអញ្ជើញអ្នក - នាង - មីង - យាយ... មកអង្គុយកន្លែងខ្ញុំចុះ" ។ បិច្ចនេះមិនចំពោះតែត្រង់រូបស្ត្រីទេ ប្រសិនបើមានចាស់ជរាគ្រាំគ្រាណាស់ហើយ។ គ្មានកន្លែងអង្គុយ បុរសដែលក្មេងនៅមានកំលាំងឈរបាន គប្បីប្រណីដល់មនុស្សចាស់ ជរាបអញ្ជើញគាត់ឱ្យមកកាន់កន្លែងយើង ដោយសេចក្តីមេត្រីរាប់អានទុកដូចជាជីតារបស់យើង ។ យ៉ាងនេះគេសន្មតថាយើងមានធម៌គោរពចាស់ទុំ នឹងស្ត្រីពេញបរិបូរណ៍ ។

## ~ចំពោះព្រះសង្ឃ~

កិច្ចគោរពព្រះសង្ឃតាមរទេះ - ទូក - កប៉ាល់ ... ។ល។ ក៏មិនប្លែកពីគោរពមនុស្សចាស់ និង ស្ត្រីឡើយ ។ ប៉ុន្តែត្រូវដឹងថាគ្រហស្ថទាំងអស់គ្នាត្រូវគោរពព្រះសង្ឃទាំងអស់អង្គដែលយើងឃើញថាលោកគ្មានទីគង់ នោះទោះស្ត្រីក្តី បុរសក្តី គប្បីក្រោកឈរយកកន្លែងប្រគេនលោក ត្រង់នេះត្រូវបុរសបំពេញកិច្ចនេះមុនស្ត្រី លុះត្រាតែរស់បុរសក្នុងទីនោះហើយ ទើបត្រូវស្ត្រីដែលនៅក្មេង នៅមានកំលាំងឈរបានយូរបំពេញកិច្ចគោរពនេះតទៅទៀតជាលំដាប់ ។

ចុះបើព្រះសង្ឃ និងព្រះសង្ឃដូចគ្នា នោះខ្ញុំមិនអាចនឹងអធិប្បាយបានឡើយ ដោយបព្វជិតមានក្រិត្យវិន័យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ព្រាស់បញ្ញត្តិទុកមកស្រាប់ហើយ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## -អង្គុយក្នុងរថ-

នឹងលើកយករថយន្តមកបង្ហាញ ជាបែបផែនជូនជាគំរូអំពីទីអង្គុយក្នុងរទេះ ។

រថយន្តដែលជាយានសំរាប់ផ្ទាល់ខ្លួន រមែងមានទីអង្គុយពីរសង្កាត់ដាច់ពីគ្នា មុខក្រោយ អាចឱ្យយើងសំគាល់បានថាខាងមុខទន្ទឹមនឹងអ្នកបរនោះ ចាត់ជាទីបន្ទាប់ ខាងក្រោយចាត់ជាទីខ្ពស់ ។ ដូច្នេះគេគប្បីសំគាល់បានថា អ្នកធំ ឬអ្នកម្ចាស់រទេះ តែងអង្គុយខាងក្រោយ អ្នកតូចតែងតែអង្គុយខាងមុខជាមួយនឹងអ្នកបរជាទម្លាប់១ តែយ៉ាងនេះក៏មិនទៀងទៀត ។

ត្រូវចាត់របៀបដូចមានតទៅ :

១- បើប្រសិនគេឱ្យរថយន្ត ១ ទៅទទួលនិមន្តលោកសង្ឃពីវត្តមកផ្ទះគេ ព្រះសង្ឃគប្បីនិមន្តលោកគ្រូដែលចាស់វស្សា ដូចជាលោកគ្រូចៅអធិការក្ដី ឬគ្រូសូត្រក្ដី ឬព្រះរាជាគណៈឋានានុក្រមក្ដី ឱ្យគង់ខាងក្រោយ លោកដែលខ្ចីវស្សាដែលគ្មានយសសក្តិ ត្រូវគង់ខាងមុខទើបគួរ ។ នេះនិយាយអំពីរថយន្តតូច១ (រថគីង) ។ បើជារថធំ កាមីញ៉ុងវិញដែលមានចំណេះច្រើន នោះត្រូវរៀបលោកគ្រូធំ១ ឬ ចាស់១ មកគង់ជាមួយនឹងអ្នកបរខាងមុខវិញ ដាក់លោកអណ្ដាប់មកខាងក្រោយវិញតាមលំដាប់ទើបគួរ ។

២- បើអ្នកធំលោកហៅឱ្យយើងជិះរទេះជាមួយនឹងលោក យើងគប្បីជិះទន្ទឹមនឹងអ្នកបរ លើកតែលោកហៅយើងទៅអង្គុយជិតលោក នោះទើបគប្បីទៅបាន បើត្រឡប់ជាយើងមានរទេះ ហើយអញ្ជើញលោកអ្នកធំវិញនោះគប្បីប្រើរបៀបតែមួយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

តែត្រូវយើងជាម្ចាស់រទេះបើកទ្វាររទេះអញ្ជើញលោកឱ្យឡើងមុន ។

៣- អញ្ជើញមិត្រភក្តិសក្តិស្មើគ្នាឱ្យជិះរទេះជាមួយ បើតែពីរនាក់នឹងយើង នោះត្រូវអង្គុយទន្ទឹមគ្នាខាងក្រោយ បើយើងបររទេះខ្លួនយើងត្រូវអង្គុយទន្ទឹមគ្នាខាងមុខ ។

៤- ត្រូវកុំភ្លេចថាយើងជាម្ចាស់រទេះ ត្រូវបើកទ្វាររទេះអញ្ជើញភ្ញៀវឱ្យឡើងអង្គុយមុន តាមកន្លែងដ៏សមគួរអស់ហើយ បិទទ្វាររទេះឱ្យមាំទាំហើយ សឹមយើងឡើងជាក្រោយ ។

៥- បើចៅហ្វាយនាយ ប្រើយើងទៅណាមកណាហើយបង្គាប់ថា ឱ្យយករទេះលោកជិះជូនទៅ នោះយើងមិនត្រូវទៅរង្គុយទីខ្ពស់ទេ គឺទីកន្លែងដែលលោកធ្លាប់អង្គុយ យើងត្រូវអង្គុយនៅទីបន្ទាប់ ទន្ទឹមជិតអ្នកបរ លើកតែរទេះដែលមានកន្លែងអង្គុយតែ ១ ឬតែ ពីរប៉ុណ្ណោះ ។

## ឥរិយាបថទី ៣

### ~ឈរ~

ឈរជាឥរិយាបថទី ៣ នៃធម្មជាតិមនុស្សដែលកាលនៅជាទារក មាតាបិតាបង្ហាត់បង្រៀនឱ្យរៀនឈរមុនរៀនដើរ ក្រោយចេះអង្គុយ ។

ដល់យើងបានធំរីកធំឡើង មានវ័យជាបឋម មាតាបិតានឹងគ្រូអាចារ្យបានហ្វឹក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ហ្វឹនប្រដៅឱ្យដឹងខុសត្រូវ នឹងគួរសមក្នុងឥរិយាបថទាំង ៤ ទៀត ។

ឥរិយាបថឈរនេះ ក្នុងត្រកូលដែលធ្លាប់មានសុខភាពរៀបរយល្អប្រដៅកូនចៅថា :

បើម្តាយ-ឪពុក-ជីដូន-ជីតា-គ្រូអាចារ្យ អង្គុយរាបហើយហៅកូនចៅ នឹងសិស្សឱ្យចូលមកជិតក្តី ឬកូនចៅ សិស្សគណាមានការចូលទៅជិត នឹងជំរាបការផ្សេងៗក្តី មិនត្រូវឈរនិយាយ ទោះជាបេកវត្ថុអ្វីទៅជូន ក៏មិនត្រូវឈរហុចដែរ ។

តែបើលោកអង្គុយរាបនៅលើផ្ទះ ឬ លើគ្រែដែលជាសេនាសនៈខ្ពស់ជាងទៅហើយ យើងនៅទីទាបជាង គប្បីឈរនិយាយបានមិនជាការឆ្គងទេ ក៏ប៉ុន្តែត្រូវបន្ទន់ខ្លួនបន្តិច ដើម្បីសម្តែងគារវកិច្ចគោរពបុព្វការីជនឱ្យបរិបូណ៌ ។

ចំណែកខាងគារវកិច្ចចំពោះខត្តិយត្រកូល មានព្រះមហាក្សត្រិយ៍ជាដើម ការឈរនិយាយថ្វាយសេចក្តីផ្សេងៗ នោះខ្ញុំបានអធិប្បាយហើយក្នុងឥរិយាបថអង្គុយ ។

## ~ឈរនៅទីប្រជុំ~

មានកាលនៅទីប្រជុំអ្វីមួយ ពេលឈរផ្តុំប្រជុំគ្នាជាវង់ ដោយពួក ដោយក្រុម ដើម្បីសន្ទនានោះអ្នកទាំងឡាយដែលឈរក្នុងវង់ ត្រូវរំពៃប្រយ័ត្នក្នុងគារវកិច្ចនៃឥរិយាបថដែលឈរនោះ ក៏ត្រូវកុំឈរប្រកិតជិតលោកដែលមានយសសក្តិធំជាងខ្លួន ឬលឿនលយចូលទៅទន្ទឹម ។ មិនតែប៉ុណ្ណោះទេ ត្រូវរារាំងទាំងជើងដៃទៀតផង ។ មិនត្រូវយក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដៃច្រត់ចង្កេះ លូកក្នុងហោប៉ៅខោ ហោប៉ៅអាវ បោះជើងទៅមុខ ទៅក្រោយ ចំទែងកន្ទែក យោលខ្លួនប្រាណឡើយ ព្រោះជាការខ្វះនូវកិរិយាគោរពដល់ចាស់ព្រឹទ្ធាចារ្យ នឹងមន្ត្រីធំ តូច ដែលរួមប្រជុំជាមួយផង ។

ចុះបើយើងឈរប្រជុំជាមួយនឹងមិត្រស្និទ្ធរបស់យើងនោះ កិច្ចការវៈជាធម្មតាតាមសមគួរមើលដល់ភ្នែកអ្នកដទៃឱ្យផុតសេចក្ដីរិះគន់ ។

## ឈរជិតអ្នកអង្គុយ

នៅទីណាក៏ដោយ បើមានគេអង្គុយរាបក្ដី អង្គុយកៅអីក្ដី យើងមិនត្រូវទៅឈរជិតហួសប្រមាណទេ គឺឈរស្ទើរតែជាន់គេ ឬវាសដៃលើកដាក់ចុះឡើង ស្ទើរតែប៉ះខ្លួនប្រាណគេ យ៉ាងនេះត្រូវប្រយ័ត្នឱ្យណាស់ ព្រោះមានកាលបរេច្ឆេទទៅជាជម្លោះប្រមាថគ្នាក៏មាន វាយតប់គ្នាក៏មាន ។ តែបើយើងភ្លេចស្មារតី លើកដៃទៅប៉ះអ្នកនៅឈរជិតខាងគ្នាដោយឥតមានបំណង នោះយើងគប្បីបន្ទឺនូវវាចាថា "សូមទោស" ដោយសំឡេងទន់សុភាព ។ អ្នកដែលត្រូវគេប៉ះពាល់នោះគប្បីអត់នូវទោសនោះឱ្យអ្នកដែលសូមទោស ដោយប្រើប្ញកពាក្យមិនខឹងសម្បារ មិនប្រើកិរិយាកញ្ចុកកញ្ចូវឡើយ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## -ក្រោកឈរ-

កាលយើងនៅសាលារៀន លោកគ្រូយើងប្រដៅឱ្យក្រោកឈរគំនាប់គួរសម ចំពោះភ្ញៀវដែលចូលមកក្នុងបន្ទប់យើងរៀន មានលោកចាងហ្វាងសាលាជាដើម ។ រាល់ថ្ងៃដែលយើងចូលទៅរៀន យើងត្រូវពលរគោរពលោកគ្រូយើងសិន ទាល់តែលោកគ្រូឱ្យអង្គុយទើបហ៊ានរង្គុយ ។ ដល់ពេលចេញពីរៀនទៀត លោកគ្រូយើងបង្គាប់ឱ្យ ក្រោកពលរសិន ទើបឱ្យចេញទៅក្រៅ ។ ការវៈនេះជាកិច្ចប្រសើរល្អណាស់ សំរាប់បង្ហាត់សិស្សានុសិស្សឱ្យចេះគោរពចាស់ គោរពគ្រូរអាចារ្យ គោរពអ្នកធំ កាលមកដល់ទីឯកាលត្រឡប់ទៅវិញ ។

ដូច្នេះ កិច្ចក្រោកឈរគោរពនេះបានតទៅទៀតជាច្រើនប្រភេទ ច្រើនសណ្ឋាន ។

## -នៅក្នុងកន្លែងធ្វើការ-

នៅក្នុងកន្លែងធ្វើការ ក៏ដូចនៅកន្លែងរៀន ។ អ្នកធ្វើការទាំងរស់សុទ្ធតែរង្គុយនៅកៅអីធ្វើការ ។ បើកាលណាចៅហ្វាយនាយចូលមកក្តី ឬមានអ្នកធំឯណាមួយចូលបករកចៅហ្វាយនាយយើងក្តី យើងគប្បីក្រោកឈរគោរពដោយបន្ទន់ខ្លួនឯក់ក្បាល ឬលើកដៃសំពះតាមការគួរ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ~នៅទីចាំផា~

យើងពុំបានទៅហែសពនឹងគេទេ យើងទៅនៅចាំមុនឯទីចាំផា ឬនៅវត្ត ។ ម្ចាស់សពរៀបកៅអីទុកបំរុងទទួលភ្ញៀវ និងញាតិមិត្រ ។ កាលណាក្បួនដង្ហែសពទៅដល់យើងត្រូវក្រោកឈរគោរពសពលុះត្រាតែគេតម្កល់ស្រេចនៅលើជើងថ្ករទើបគប្បីអង្គុយចុះទៅវិញ ។ ដល់ពេលព្រះសង្ឃនិមន្តមកបង្សុកូលទៀត យើងរាល់គ្នាត្រូវក្រោកឈរគោរពព្រះសង្ឃទៀត លុះត្រាតែលោកសូត្រចប់ត្រឡប់ទៅវិញ ។

បើមានព្រះមហាក្សត្រិយ៍ស្តេចយាងទៅផងជាព្រះរាជាធិបតី ពេលព្រះអង្គស្តេចយាងទៅព្រះរាជទានផ្កាខ្លឹមចន្ទន៍ដល់សព នោះបណ្តាជនានុជននៅទីនោះទាំងប៉ុន្មានត្រូវក្រោកឈរគោរពទាំងអស់គ្នា[១] លុះត្រាតែស្តេចយាងត្រឡប់មកគង់នៅទីប្រថាប់វិញ ។

នៅពេលដែលព្រះមហាក្សត្រិយ៍ព្រះរាជទានភ្លើងសពនេះទៀត ឬបើជាសពធម្មតាដែលគ្មានព្រះមហាក្សត្រិយ៍ កិច្ចរំលាយសពធ្វើតាមទម្លាប់ទំនៀមប្រវេណីពីបុរាណមក គឺមានអាចារ្យយោគីខាងមុខ អ្នកភ្លុក៤ខាងក្រោយ ដើរបណ្តោយគ្នាប្រទក្សិណសពហើយឆួលភ្លើង នោះយើងរាល់គ្នាគប្បីក្រោកឈរគោរពជូនដំណើរសពជាមច្ឆិមកិច្ច ហើយគប្បីនៅស្ងៀមស្ងឹងស្ងាធ៍ ដាក់មុខឱនបន្តិច ពិចារណានូវបរណសតិរលឹកនូវសេចក្តីស្លាប់តាមពុទ្ធោវាទដែលមានច្រើនបែបច្រើនយ៉ាងណាស់

ឈរនេះរវាងប្រហែលជា ៥ នាទី នាឡិកា រួចទើបល្មមអង្គុយទៅវិញ ។

---

១ លើកតែអ្នកអង្គុយរាបផ្ទាល់ក្រាល ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ជូនកាលគេរៀបតាមភ្លេងនៃលេងជូនដំណើរភ្លើងនោះ ជាកម្រិតពេលនៃកិច្ចឈរគោរពនេះ ។

## -ឈរលេង-

ដំណើរឈរលេង ត្រូវអោយពិចារណាថា ទីកន្លែងដែលយើងឈរ តើជាទីមានទំនាស់ ឬ ទេ ? បើឃើញថាមិនទំនង ត្រូវរកកន្លែងដទៃទៀតអោយជាទីដ៏សមគួរ ។ មិនត្រូវឈរលេងនៅកណ្ដាលថ្នល់ នៅផ្លូវបត់កាច់ជ្រុង នៅហាត់ច្រក ដែលជាទីចង្អៀត នៅមាត់ទ្វារ មាត់ផណ្ដើរ ដែលនាំអោយទើសទែងដល់អ្នកគោចរ ។

## -ឈរគោរពបទចំជាតិ និងភ្លេងជាតិ-

កាលបើយើងដើរនៅថ្នល់ ឬនៅទីណាមួយ នៅប្រទះប៉ះលើពេលដែលគេកំពុងធ្វើពិធីបង្ហូតទង់ជាតិ មានផ្លុំត្រែក្ដី ឥតផ្លុំត្រែក្ដី យើងត្រូវឈប់ដើរ ឈរទីមជើងសំយុងដៃទាំងពីរ ងើបងើយក្បាលឡើយ ភ្នែកសំឡឹងទៅទង់ជាតិដែលកំពុងបង្ហូតនោះ រួចហើយសឹមដើរទៅទៀត ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទាំងភ្លេងជាតិ (នគររាជ) ក៏ដូចគ្នា បើយើងដើរក្តី នៅលើរថយន្តក្តី លើទោចក្រយានក្តី... ។ល។ បើទៅប្រទះគេកំពុងលេងភ្លេងជាតិក្នុងពិធីអ្វីមួយ ត្រូវតែប្រើកិរិយាឈប់ឈរគោរពអោយអស់រយៈភ្លេងសឹមតដំណើរទៅទៀត ។

កិច្ចឈរគោរពទង់ជាតិនិងភ្លេងជាតិនេះ ប្រសើរណាស់ សំរាប់ជនជាតិនីមួយៗ ព្រោះក្នុងសាកលលោកនេះ គេតែងតែគោរពទង់ជាតិនឹងភ្លេងជាតិគេដោយស្មោះរស់ពីចិត្តគ្រប់ៗគ្នា ។

## ឥរិយាបថទី ៤

### ~ដើរ~

ដើរជាឥរិយាបថទី ៤ មានលក្ខណៈឱ្យជាបែបបទទៅជាទម្លាប់ទំនៀមសម្រាប់អ្នកស្រុកប្រតិបត្តិដែរ ឱ្យត្រឹមត្រូវតាមគន្លងប្រវេណី ។

ដើរមានច្រើនប្រភេទ គឺដើរហែជាក្បួនជាផ្លូវការ, ដើរហែជាក្បួនធម្មតារបស់សាមញ្ញជន (មានធ្វើបុណ្យជាដើម ), ដើរហែក្សត្រិយ៍ខត្តិយវង្សផ្ទាល់ព្រះអង្គ, ដើរតាមមន្ត្រីធំ-តូចផ្ទាល់ខ្លួន, ដើរតាមមាតា-បិតា ជីដូន ជីតា គ្រូបាអាចារ្យចាស់ទុំ, ដើរជូនដំណើរភ្ញៀវ.... ។ល។ ត្រូវបំពេញការកិច្ចនេះឱ្យគ្រប់បរិបូណ៌ និងតាមទម្លាប់ទំនៀមខ្មែរ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ~ដើរក្នុងក្បួនហែ~

ក្បួនហែឯណាមួយ ដែលមានរបៀបរៀបតាមរយៈតាមសង្កាត់ អ្នកទៅជួយ ឬទៅគួរសមក្នុងបុណ្យនោះ មិនគប្បីនឹងចូលទៅដើរលាយឡំឱ្យខូចរបៀបក្បួនរបស់គេឡើយ ។

ឧបមាដូចហែសព យើងគប្បីចូលចិត្តឱ្យច្បាស់ថា យើងជាអ្នកហែក្នុងក្បួនដែលរៀបចាត់ ឬ យើងជាភ្ញៀវទៅជូនដំណើរសព ។

បើយើងជាអ្នកហែក្នុងរបៀបក្បួន យើងត្រូវស្តាប់បង្គាប់អ្នករៀបក្បួន គេឱ្យយើងដើរត្រង់ណា ត្រូវយើងដើរត្រង់ណោះឱ្យបានរៀបរយ ។ ចុះបើយើងជាភ្ញៀវ យើងជាអ្នកជូនដំណើរសព ចេញចាកចោលទីលំនៅទៅកាន់ស្មសានស្ថានស្ងាត់ ឬទៅកាន់ទីបញ្ចុះ ។ បើដូច្នេះហើយអ្នកជូនដំណើរ ត្រូវដើរតាមក្រោយសពទើបគួរ ។

អ្នកដែលត្រូវដើរពីក្រោយសព គប្បីរៀបជាលំដាប់ដូចតទៅនេះ

១- ស្ត្រី

២- បុរស

ស្ត្រីដែលជាកូនចៅ នឹងសាច់សាលោហិតរបស់សព ត្រូវដើរជាប់នឹងសពពីខាងក្រោយ រួចពទៅត្រូវស្ត្រីដែលជាមិត្រជាភ្ញៀវ ។

អស់លោកប្រុសៗ ក៏មានរបៀបដូចគ្នានឹងលោកស្រីៗដែរ តាមលំដាប់ញាតិមិត្រនឹងភ្ញៀវ ។

( ក្នុងត្រកូលខ្លះគេឱ្យកូនប្រុសដើរអមសព កូនស្រីដើរក្រោយសព ) ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ~ដើរជាមួយព្រះសង្ឃ~

ព្រះសង្ឃជាទីគោរពរបស់គ្រហស្ថគ្រប់ទីគ្រប់តំបន់ ។ ដូច្នេះបើយើងជាគ្រហស្ថ ដើរជាមួយភិក្ខុ ឬសាមណេរ នោះយើងមិនត្រូវដើរមុខ ឬទន្ទឹមស្មើនឹងលោកទេ ទោះជាបិតាក្តី ក៏ពុំគប្បីឡើយ ។

តែមានកាលខ្លះ លោកអនុញ្ញាតឱ្យគ្រហស្ថដើរមុខបាន ។ ព្រះធម្មកថិកនិមន្តទៅសម្តែងធម៌នៅគេហស្ថានឧបាសក-ឧបាសិកា លោកតែងឱ្យក្មេងដែលលីគម្ពីរដើរមុខ ។ យ៉ាងនេះគេពុំសំគាល់ត្រង់ក្មេងនោះទេ គេសំគាល់យកព្រះធម៌ដែលនៅក្នុងគម្ពីរនោះ លើកដម្កល់ឡើងឱ្យធំជាងព្រះសង្ឃ ។ តែបើព្រះធម្មកថិកអង្គណាយល់ថាក្មេងជាសិស្ស ត្រូវតែដើរក្រោយលោកគ្រូ នោះឃើញថា ព្រះធម៌ដែលមានក្នុងគម្ពីរមិនប្រសើរលើសលោកដែលចេះសំដែងធម៌ទេសនានោះឡើយ ។

លោកសន្តោសដល់អ្នកនាំផ្លូវទៀត អាចនឹងដើរមុខព្រះសង្ឃបានដោយសង្គ្រោះថាជាមគ្គុទេសក៍ ក៏ត្រូវតែត្រាយផ្លូវខាងមុខទើបស្រួលដំណើរ ។

## ~ដើរកាត់ហ្វូង~

នៅទីប្រជុំនីមួយៗ ដែលមានមនុស្សអង្គុយជីកង់ ឬឈរផ្តុំគ្នាជារង្វង់ ដោយពួកដោយក្រុម នោះអ្នកដើរទៅមក មិនត្រូវដើរកាត់ហ្វូងឱ្យសោះ ទោះបីគេឈរនិយាយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ភ្ញៀតែពីរនាក់ យើងក៏មិនត្រូវដើរកាត់គេទេ ត្រូវដើរចៀសគេចពីខាងក្រោយខ្នងគេ យ៉ាងនេះទើបគោរពជាអ្នកកាន់គារវកិច្ចចំពោះមិត្រមនុស្សដូចគ្នា ។

# កិរិយាដើរ

## -កិរិយាដើរមានច្រើនលក្ខណៈ-

១- ដើរនៅមុខព្រះភ័ក្ត្រ ព្រះបហាក្សត្រិយ៍ ។ នោះបើព្រះអង្គគង់រាប បណ្ដាខ្ញុំរាជការដែលនៅគាល់បំរើផ្ទាល់ព្រះអង្គដែលចូលថ្វាយវត្ថុអ្វីជាដង្វាយ តែតែងតែដើរដំណើរទាបហៅថាដើ "ទា" គឺដើរនឹងចុងជើងទាំងពីរ ក្បាលជង្គង់ (ឆ្វេង) ១ ដៃឆ្វេងច្រត់ ដៃស្ដាំកាន់អីវ៉ាន់ថ្វាយ ។ បើដើរចូលទៅដោយគ្មានកាន់អ្វីទេ នោះត្រូវផ្លាស់ឆ្វេងម្ដង ស្ដាំម្ដង ។ របៀបដើរ "ទា" នេះ គេដើរពីចម្ងាយប្រហែល ៥ ម៉ែត្រ ចូលទៅ ។

បើនឹងវិលមកវិញ ក៏តោងដើរបែបនេះដែរ តែថយក្រោយឱ្យផុតចម្ងាយ ៥ ម៉ែត្រ នេះ ទើបបង្វិលខ្លួនតាមធម្មតា ។

២- ដើរជិតអ្នកធំ ឬ បុព្វការីជន ។

បើអ្នកមានបណ្ដាស័ក្តិ ឬ នាយចៅហ្វាយ មាតា បិតា គ្រូអាចារ្យ ចាស់ទុំ អង្គុយរាបក្ដី ណើតៅអីក្ដី យើងដើរទៅជិតគប្បីបន្ទន់ខ្លួនឱនបន្ដិច ជាកិច្ចគារវៈចំពោះលោកទាំងនោះ នេះជាទំលាប់ទំនៀមរបស់ខេមរជាតិពីបុរាណរៀងមក ។ តែបើយើងចូល

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក្នុងចំណោមបរទេស នោះគប្បីមើលតាមកាលៈទេសៈ ព្រោះដូចជា ថៃ និង លាវ ក៏មានទំលាប់ទំនៀមត្រូវៗគ្នានឹងខ្មែរដែរ. ក៏ឯជនប្រទេសអឺរ៉ុបវិញ នោះយើងគប្បីធ្វើតាមវារ្យធម៌គេ ដើម្បីកុំឱ្យឈ្លើយ ។

៣-ដើរកន្លងគេ ។

យើងបានដឹង បានឃើញជាក់ថា ជនជាតិបារាំងក្តី ចិន យួនក្តី ឥតមានប្រកួតប្រកាន់ក្នុងដំណើរដើរកន្លងអ្នកដទៃឡើយ កុំតែដើរជាន់ ។

ចំណែកខ្មែរ-ថៃ-លាវ យើងប្រកាន់ណាស់ មិនត្រូវដើរកន្លងជើង-ដៃអ្នកដទៃអោយសោះ នេះជាច្បាប់ទំលាប់មួយសំខាន់ណាស់ សំរាប់សាសន៍ទាំងបីនេះ ។

## ដំណើរដើរកន្លងនេះមានត្រួតណាមច្រើន ខ :

ក) - គេមិនដើរកន្លងព្រះរូបព្រះពុទ្ធ ព្រះរូបម្ចាស់ផែនដី (ព្រះឆាយាលក្ខណ៍) រូបមាតាបិតា រូបគ្រូបាអាចារ្យ រូបព្រះចេតិយ និងរូបបុព្វការី... ។ល។

ខ) - គេមិនត្រូវដើរកន្លងគម្ពីបាលី ដែលមានធម៌អាថ៌ ។

គ) - គេមិនដើរជាន់ ឬកន្លងកន្លែងសំណឹងព្រះភិក្ខុសង្ឃ សាមណេរនេះ១ កន្ទេលពូកដែលជាដំណេកមតាបិតា ជីដូន ជីតានេះ១ ។

ឃ) - គេមិនដើរជាន់ ឬកន្លងព្រំចៀម ដែលជាទីគង់នៃព្រះមហាក្សត្រនេះ១។

ង) - គេមិនដើរជាន់ ឬកន្លងព្រំកំរាល ដែលគេរៀបជាមង្គលសិរីសួស្តីនេះ១ (ដូចជាកន្លែងរៀបសំពះការអាពាហ៍ពិពាហ៍) ។

តែបើមានកិច្ចត្រូវកាត់ឆ្លងទៅម្ខាង នោះត្រូវពរកាត់កំរាល ឬ ព្រំនោះឡើង

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ហើយវារកាត់ទៅទើបសមគួរ ។

ច)- នៅមុខព្រះពន្លា ដែលជាទីប្រថាប់នៃព្រះមហាក្សត្រិយ៍ក្នុងពិធីអ្វីមួយនោះបើព្រះមហាក្សត្រិយ៍ស្ដេចយាងមកគង់ប្រថាប់នៅទីនោះហើយ បណ្ដាពលរដ្ឋមិនត្រូវដើរកាត់ឆ្លងពីម្ខាងទៅម្ខាងទេ បើយើងមានការត្រូវចាត់ចែងនូវកិច្ចផ្សេងៗគប្បីរកច្រកដើរចំហៀង ឬពីក្រោយ ។ តែបើទាល់ទីរកផ្លូវដើរមិនបាន ត្រូវដើរទៅថ្វាយបង្គំសិន សឹមក្រោកដើរទៅទៀតទើបសមគួរ ។

ឆ)- ដំណើរដើរនៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រិយ៍ មិនត្រូវបង់បោយឱ្យសោះ ត្រូវតែផ្គុំដៃទាំងពីរពីខាងមុខ ហើយឱនក្បាលឱ្យទាបបន្តិចដើរទៅ លុះត្រាតែផុតទៅទើបប្រើដំណើរដូចដើមវិញ ។

## -បង្វិលខ្លួន-

នៅចន្លោះអង្គុយ-ឈរ និងដើរ នៅមានដំណើរបង្វិលខ្លួនជាកិរិយាបថមួយទៀត ដែលយើងត្រូវបំពេញបង្គ្រប់ឱ្យសមរម្យក្នុងគារវកិច្ច ។

យើងអង្គុយកៅអីនៅចំពោះមុខអ្នកធំ និងបុព្វការីជាជនដែលយើងគប្បីគោរព បើយើងនឹងលាវិលវិញ ត្រូវក្រោកឈរឡើងធ្វើគារវកិច្ច ដោយសំពះលាម្ដងទៀត ឬឱនក្បាលម្ដងទៀតដើរថយក្រោយបានពីរ ឬ បីជំហានសឹមបង្វិលខ្លួន បែរមុខទៅរក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទ្វារដែលត្រូវដើរចេញទៅ ។

ដំណើរបង្វិលខ្លួននេះ បើយើងចូលគាល់ព្រះមហាក្សត្រិយ៍នោះត្រូវប្រយ័ត្នកិរិយាបថនេះឱ្យមែនទែន. ទោះជាអង្គុយគាល់រាបក៏ដោយ កាលយើងក្រាបថ្វាយបង្គំលារួចហើយ ត្រូវវារថយក្រោយបានពីរ ឬបីជំហានសិន ទើបត្រូវបង្វិលខ្លួនហើយក្រោកដើរចេញទៅ ។

ដំណើរបង្វិលខ្លួននេះមានឧទាហរណ៍មួយទៀតជាសំខាន់ណាស់ ។ យើងទៅលេងផ្ទះគេ លាគេវិលវិញ ម្ចាស់ផ្ទះប្រកាន់ការគួរសមដោយគោរព ក៏ជូនដំណើរយើងដល់មាត់ទ្វារផ្ទះក្ដី មាត់ទ្វាររបងភូមិក្ដី នោះនៅពេលចេញផុតទ្វារត្រូវបង្វិលខ្លួនបែរមុខទៅរកម្ចាស់ផ្ទះវិញ ហើយធ្វើគារវកិច្ចម្ដងទៀតដោយសំពះ ឬងក់ក្បាល ។

ដំណើរបង្វិលខ្លួននេះមានលក្ខណៈមួយ ដែលយើងកុំគប្បីធ្វេសឱ្យសោះ កុំឱ្យភ្លាត់បាន គឺកុំបង្វិលខ្លួនបែរខ្នងទៅអ្នកធំដែលនៅក្នុងទីប្រជុំ ។

ប្រៀបដូចជារបាំដែលសំដែងរបាំនៅលើឆាក នេះតាមរបៀបរបាំវិរិរុប គេបង្ហាត់ល្ខោន គេមិនឱ្យបង្វិលខ្លួនបែរខ្នងទៅឱ្យអ្នកមើលទេ ទោះយ៉ាងណាក៏ដោយក៏ត្រូវតែបែរចំហៀងខ្លួនឱ្យស្រួល ។

អធិប្បាយប៉ុណ្ណេះក៏ល្មមលោកអ្នកស្ដាប់បាន ល្មមចូលចិត្តបានក្នុងដំណើរបង្វិលខ្លួននេះ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ~ក្អក~កណ្តាស~

នៅនាប្រជុំធំក្តី-តូចក្តី ដំណើរក្អក-កណ្តាស ជាឧបសគ្គឱ្យរំខានដល់អ្នកសំដែងនូវសេចក្តីផ្សេងៗ និងអ្នកស្តាប់ទាំងពួងក្នុងទីប្រជុំនោះ ។

បើក្អក-កណ្តាសកើតឡើងបន្តិចបន្តួចដោយឈ្លក់ខ្យល់ ឬឈ្ងុលច្រមុះនឹងក្លិនឬផង់ធូលី វត្ថុអ្វីមួយនោះ មិនជាការរំខានដល់គេឯងផងទេ អាចនឹងទ្រាំខ្ទប់មាត់ ខ្ទប់ច្រមុះទៅបាន ។ តែបើខ្ទប់ហាត់ខ្ទប់ច្រមុះហើយពុំស្រាន្ត យើងគប្បីក្រោកចាកទីនោះសិន ចេញឆ្ងាយទៅរកឧបាយបំបាត់រោគនេះសិនសឹមចូលមកវិញ ។ យើងត្រូវចាំថា បើក្អក-កណ្តាស ត្រូវយកកូនកន្សែងខ្ទប់មាត់ ខ្ទប់ច្រមុះជាដរាប ប្រយោជន៍កុំអោយឮសូរខ្លាំង កុំឱ្យចេញទឹកមាត់-ទឹកសំបោរពាចព្រោះព្រាយសាចទៅលើគេឯងដែលអង្គុយជិតខាងផងគ្នា ។ យើងត្រូវកុំភ្លេចថា បើនឹងក្អក កណ្តាស ត្រូវបែរមុខចេញអំពីមុខគេ ឬត្រូវដើរចេញឱ្យឃ្លាតឆ្ងាយពីគេឯង ទៅបន្ទោរបង់នូវក្រខ្វក់គឺកំហាក-ស្លេស្ម សម្បោរ-ទឹកមាត់ឱ្យអស់សិន ហើយជូតមាត់ច្រមុះអោយស្អាតបាតសឹមវិលចូលមកកាន់ទីដើមវិញទើបសមគួរ ។

## ខាក~ស្តោះ

រោគក្អក - កណ្តាស នេះរមែងមានការខាកស្តោះជាប់តមកជាលំដាប់ ។

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

ដូច្នេះតែខាកហើយត្រូវស្តោះជាចម្មតា ។ ត្រូវស្តោះដាក់កន្ថោរ នៅទីណាដែលគេដាក់កន្ថោរបំរុងឱ្យ ។ បើវគ្មានកន្ថោរត្រូវស្តោះដាក់កូនកន្សែង (ហោប៉ៅ) រួចសឹមយកទៅដុសលាងជាក្រោយ ។

យើងមិនត្រូវខាកស្តោះឱ្យសោះ :

១- នៅទីណាក៏ដោយដែលគេសំអាតល្អ ។

២- នៅលើឥដ្ឋ ឬក្តារក្រាលផ្ទះ - សាលា... ។ល។

៣- នៅជើងសសរ និងជើងជញ្ជាំងផ្ទះ - សាលា... ។ល។

៤- តាមបង្អួចផ្ទះ - សាលា... ។ល។ (ទៅដី) ខ្លាចក្រែងទៅលើគេដែលនៅខាងក្រោម ។

៥- បើមានអ្នកឯណាមួយដើរមកប៉ះប្រទះមុខយើង យើងត្រូវបង្អង់ឱ្យគេដើរហួសទៅសិន ។

៦- បើយើងឈរ ឬអង្គុយនិយាយគ្នាតែពីរអ្នកក្តី ច្រើនអ្នកក្តី នៅចំពោះមុខអ្នកទាំងនោះ ត្រូវបែរមុខចេញសឹមស្តោះ ។

៧- នៅទីជិតខាងគេឯងដែលកំពុងបរិភោគអាហារ ។

៨- នៅភត្តាគារដែលជាទីប្រជុំជនច្រើន បរិភោគខាទនីយភោជនីយាហារ ។

ឯការខាក បើត្រូវការខានពុំបានដោយឃាត់ពុំឈ្នះ ត្រូវខាកតិច១ កុំឱ្យកើតខ្ពើមរអើមដល់គេឯង ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ~ស្ងាប~

ស្ងាបជាកិរិយាដែលបើកមាត់ធំ ហើយដកដង្ហើមវែងបញ្ចេញខ្យល់មកឮសូរហូមៗ ។ ស្ងាបនេះយើងពុំមែនក្លែងធ្វើទេ គឺបណ្ដាលពីការនឿយហត់អស់កំលាំង ហើយងងុយដេកក៏បាន បកពីអត់ងងុយក៏បាន ឬដល់ពេលងងុយតាមធម្មតាក៏បាន ។

មានកាលយើងងងុយពេក ស្ងាបទៅចេញទឹកភ្នែក ទឹកសម្បោរផងក៏មាន ។

ដំណើរហាមាត់ស្ងាបឱ្យអស់ចំហជាកិរិយាមិនល្អមើល ថែមបន្លឺនូវសូរហូមៗទៀត ជាសព្ទមិនពិរោះស្ដាប់សោះ ។ ហេតុនេះកាលណាយើងស្ងាបនៅទីណាក៏ដោយ សូម្បីនៅតែម្នាក់ឯង ក៏គប្បីយកកូនកន្សែង ឬយកដៃខ្ទប់មាត់ ដែលការនោះជាដរាបជាទំលាប់ ដើម្បីកុំឱ្យធ្លាប់ភ្លេចខ្លួនទៅៗ ហាមាត់នៅកណ្ដាលប្រជុំជន ។

បើកាលណាយើងដឹងខ្លួនថា ចង់ស្ងាបហើយ យើងត្រូវប្រញាប់រវៀសរវៃប្រុងខ្លួន និងកុំឱ្យឮហូមៗ និងយកដៃ ឬកូនកន្សែង ខ្ទប់មាត់ ខ្ទប់មុខ និងជូតមុខ ជូតភ្នែកឱ្យស្អាតវិញដូចដើម ។

## បង្គំ~សំពះ

ពាក្យ "បង្គំ" ជាគូនឹងពាក្យ "សំពះ" គឺអំពើគោរព ចំពោះត្រង់អ្នកដែលគួរគោរព ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

"បង្គំ" និង "សំពះ" មានកិរិយាមិនដូចគ្នាទេ យើងត្រូវប្រយ័ត្នកុំឱ្យច្រឡំភ័ន្ត។ កិរិយា "បង្គំ" មានច្រើនបែប "សំពះ" ក៏មានច្រើនបែបដែរ ។

១- "បង្គំ" ប្រើក្នុងព្រះពុទ្ធសាសនា សំរាប់និយាយថា "ថ្វាយបង្គំព្រះ" "ថ្វាយបង្គំលោកសង្ឃ"

របៀបថ្វាយបង្គំនេះ មានបែបផែនដូចមានតទៅ គឺអង្គុយប្រហោង តួយដៃទាំងពីរដាក់លើក្បាលជង្គង់ ចុងដៃផ្គុំគ្នាទាំងពីរលើកឡើងនៅប្រជុំចិញ្ចើម បើក្រាបចុះទៅ ត្រូវឱ្យក្បាលជង្គង់-គួយដៃ ក្បាលឱនឱ្យដល់កន្ទេល យ៉ាងនេះបានពេញលក្ខណៈ ហៅថា "ថ្វាយបង្គំព្រះ ថ្វាយបង្គំលោកសង្ឃ" ។ បើយើងអង្គុយបត់ជើងរាបវិញ យើងត្រូវប្រឹងឱនក្បាលឱ្យដល់កន្ទេល ដាក់តួយដៃទាំងពីរឱ្យដល់កន្ទេល ។

តែបើនៅទីដីដែលយើងអង្គុយពុំកើត នោះយើងគប្បីផ្គុំដៃទាំងពីរប្រណម្យលើកឡើងដាក់ដល់ប្រជុំចិញ្ចើម ឱនក្បាលបន្ទន់ខ្លួនទៅខាងមុខ ឱ្យល្មមសមគួរ យ៉ាងនេះក៏បរិបូរណ៍ក្នុងការកិច្ចថ្វាយបង្គំព្រះ និងលោកសង្ឃ ។

## ២~ ក្នុងពាក្យរាជសព្ទ

គេប្រើសំរាប់និយាយខាងក្សត្រិយ៍ខត្តិយត្រកូល ។ គេនិយាយថា "ក្រាបបង្គំគាល់ ឬក្រាបថ្វាយបង្គំគាល់" គឺចូលក្រាបថ្វាយបង្គំ ហើយអង្គុយគាល់ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

"ក្រាបបង្គំទូល" គឺចូលក្រាបថ្វាយបង្គំទូលផ្ទាល់មាត់ ឬ ក្រាបទូលដោយលិខិត ។ "ថ្វាយបង្គំ ឬក្រាបថ្វាយបង្គំ" គឺសំពះ ឬ ក្រាបសំពះដោយគោរព ។

ក-) របៀបថ្វាយបង្គំព្រះមហាក្សត្រិយ៍ និងក្សត្រិយ៍គ្រប់ព្រះអង្គ ។

ត្រូវអង្គុយលុតជង្គង់ លើកដៃប្រណម្យនៅដើមទ្រូង បន្ទន់ខ្លួនឱនចុះទៅពាក់កណ្ដាល ដៃទាំងគូរដាក់ដល់កន្ទេល ហើយលើកឡើងទទួលក្បាលនិងប្រជុំចិញ្ចើម រួចងើបឡើងអង្គុយម៉បពាមទម្លាប់ ។

( ត្រង់នេះកុំឱ្យច្រឡំនឹងថ្វាយបង្គំព្រះ និងលោកសង្ឃ)

បើនៅទីដដែលយើងលុតជង្គង់បិនកើតបានត្រឹមតែឈរ នោះត្រូវប្រើរបៀបតែមួយ ខ្វះតែអង្គុយប៉ុណ្ណោះ ។

ខ-) របៀបថ្វាយបង្គំ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងក្នុងព្រះរាជពិធីទ្វាទសមាស ដែលទ្រង់ប្រោសព្រះរាជទាននាហ្មឺនសព្វមុខមន្ត្រីធំតូចគ្រប់ដំណែង ចូលក្រាបបង្គំគាល់ក្នុងព្រះទីន័ងទេវាវិនិច្ឆ័យ ហើយព្រះរាជទានកៅអីឱ្យអង្គុយគាល់ ។

របៀបនេះត្រូវរៀបឡើងតាមសម័យអារ្យធម៌អឺរ៉ុប ក្នុងនាចុងរាជ្យព្រះបាទសម្ដេចព្រះស៊ីសុវត្ថិចបចក្រពង្ស ព្រះចៅព្រះរាជាណាចក្រកម្ពុជាធិបតី តែពុំបានផ្លាស់ចោលទាំងរបស់ទេ គ្រានីតែប្ដូររង្គុយរាបនឹងកៅអីប៉ុណ្ណោះ ។

គ)- របៀបថ្វាយបង្គំដែលអង្គុយកៅអី គឺក្រោកឈរទឹមជើងសំយ៉ុងដៃទាំងពីរឱ្យត្រង់ចុះ ។ រួចលើកឡើងប្រណម្យនៅដើមទ្រូង ឱនក្បាលចុះ លើកដៃទាំងពីរទទួលក្បាលនៅត្រង់ប្រជុំចិញ្ចើម ទំលាក់ដៃទាំងពីរប្រណម្យមកត្រឹមដើមទ្រូង ទាំង

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ងើមក្បាលឡើងឱ្យត្រង់ឱ្យស្មើគ្នា រួចទើបសំយុងដៃទាំងពីរចុះតាមដងខ្លួនដូចដើមវិញ ។

របៀបនេះ បើត្រូវថ្វាយបង្គំពាដងតាមពិធីធំតូច គឺត្រូវធ្វើដដែលទៀត ឱ្យគ្រប់ពាដងទើបអង្គុយចុះ ។

ក្នុងព្រះរាជពិធីធំៗក្នុងព្រះទីន័ងទេវាវិនិច្ឆ័យ មានភ្នាក់ងារម្នាក់ មុខក្រសួងខាងក្រុបព្រះរាជមន្ទីរ វាយគងជាសំគាល់សំរាប់ឱ្យបន្ទ្រីធំតូចថ្វាយបង្គំ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងឱ្យល្បបរបៀបរយព្រមគ្នា ។

ឃ) - របៀបថ្វាយបង្គំក្សត្រិយ៍

ទីព្រះអង្គម្ចាស់ និងអ្នកអង្គម្ចាស់

បើអង្គុយរាប ត្រូវយកដៃទាំងពីរមកផ្ទុំនៅដើមទ្រូង បន្ទន់ខ្លួនឱនក្បាលបន្តិចទៅមុខ ឱ្យចុងដៃជួបនឹងចុងច្រមុះរួចងើបឡើងឱ្យត្រង់ខ្លួន ដាក់ដៃទាំងពីរទៅលើភ្លៅដាក់ក្បាលឱ្យឱនបន្តិច កុំងើបខ្លាំងឱ្យហួសប្រមាណទាល់តែខូចឫកពាយើងដែលរៀបចំខ្លួនគោរព ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ~សំពះ~

សំពះគឺលើកដៃទាំងពីរផ្ទុំឡើងឆ្ពោះត្រង់ ទៅរកបុគ្គលណាមួយ ឬទៅរកវត្ថុអ្វីមួយដែលគួរគោរព ។

ពាក្យ "សំពះ" ប្រើច្រើនបែបដូចគេនិយាយថា : សំពះការ គេយកកូនស្រីនិងកូនប្រុសឱ្យមកក្រាបសំពះផ្ទឹមគ្នា ក្នុងវេលារៀបរាពេហ៍ពិពាហ៍ឱ្យជាភរិយាស្វាមី ។

"សំពះគ្រូ" គឺសំពះគោរពចំពោះគ្រូ ឬ ចំពោះគុណ ។

"សំពះសុំទោស" គឺសំពះអង្វរសុំឱ្យអត់ទោសឱ្យ ។

ក្នុងទីនេះ ត្រូវអធិប្បាយឱ្យក្បោះក្បាយបន្តិចអំពី "សំពះសួរ" និង "សំពះលា" ។

## សំពះសួរ និង សំពះលា

គឺសំពះបុគ្គលណាមួយដែលគួរគោរព ហើយបញ្ចេញវាចារសួរសុខទុក្ខផងជាការគួរសម ។

ដំណើរ "សំពះ" នេះ ត្រូវក្មេងសំពះសួរចាស់មុន គឺត្រូវកូនសំពះមាតា-បិតា ចៅសំពះជីដូន-ជីតា, ក្មួយសំពះមា-មីង, ប្អូនសំពះបង, សិស្សសំពះគ្រូអាចារ្យ (គ្រហស្ថ) អ្នកតូចសំពះអ្នកធំ, រាស្ត្រសំពះមន្ត្រី ... ។ល។ ត្រង់បុព្វការីគឺ ឪពុកម្តាយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ជីដូន ជីតា កុំគប្បីសំពះតបទៅកូនចៅវិញឡើយ ទុកជាបានបុណ្យសក្តិធំយ៉ាងណាក៏ដោយ ។

## ~លក្ខណៈសំពះ~

១- កូនស្រី កូនប្រុស សំពះមាតា បិតា

ចៅ សំពះជីដូន ជីតា

សិស្ស សំពះគ្រូអាចារ្យ

គប្បីលើកដៃប្រណម្យដាក់ដល់ប្រជុំចិញ្ចើម ។

២- ខ្ញុំរាជការ - ភ្នាក់ងារគ្រប់ដំណែង សំពះចៅហ្វាយនាយគប្បីលើកដៃប្រណម្យដាក់ត្រឹមមាត់ ។

៣- មនុស្សស្មើសក្តិគ្នាជាមន្ត្រីដូចគ្នា ឬ រាស្ត្រសាមញ្ញដូចគ្នា គប្បីលើកដៃសំពះគ្នាទៅវិញទៅមកត្រឹមដើមទ្រូង ។

៤- រាស្ត្រសាមញ្ញសំពះមន្ត្រីធំ ដូចជារដ្ឋមន្ត្រី ចៅហ្វាយខេត្ត ចាងហ្វាង សាលាតុលាការ... ។ល។ ( គឺមន្ត្រីដែលមានយសសក្តិជាទីឧកញ៉ា អ្នកឧកញ៉ា... ។ល។ គប្បីលើកដៃដាក់ដល់ច្រមុះ ។

សក្តិតូចចុះមក សំពះដាក់ដៃត្រឹមមាត់ក៏ល្មមហើយ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ~កិរិយាដែលសំពះ~

កិរិយាដែលត្រូវរៀបចំខ្លួនសំពះ ត្រូវផ្គុំដៃទាំងពីរឱ្យចំពីមុខនៅដើមទ្រូង បើនឹងលើកឡើងទៅលើក្តី ទាញចុះមកក្រោមវិញក្តី ត្រូវឱ្យនៅត្រង់ពីមុខដរាប កុំយកទៅដាក់ចំហៀងមុខខាងស្តាំ ឬ ខាងឆ្វេង ឬមួយយកទៅលើលើស្មា ពុំនោះសោតរុញឱ្យឃ្លាតឆ្ងាយពីខ្លួនទៅមុខ ទៅក្រោយ ដូចជាហុចអ្វីឱ្យទៅអ្នកដែលយើងត្រូវគោរពនោះ ។

កិរិយាសំពះនេះ តែកាលណាលើកដៃឡើងហើយ ត្រូវឱនក្បាលបន្តិចទើបសមរម្យ ។

សំពះជាទម្លាប់ទំនៀមខ្មែរ ប្រើសំរាប់គោរពគ្នាទៅវិញទៅមកក្នុងការកិច្ចគួរសមនឹងហៅ "សំពះសួរនិងសំពះលា" ជាធម្មតារបស់ជាតិយើង ។

## គំនាប់ឱនក្បាលចាប់ដៃ

ការកិច្ចដែលត្រូវគំនាប់គ្នាដោយកិរិយាឱនក្បាល និង ចាប់ដៃហៅនេះ ជារបៀបគួរសមគោរពហៅរបស់ជនប្រទេសអឺរ៉ុបជាដំបូង ។ សព្វថ្ងៃរបៀបនេះសាយភាយពេញលោកទាំងមូលទៅហើយ ។ តែនៅចំណែកប្រទេសអាស៊ី ប្រទេសខ្លះធ្លាប់តែសំពះគ្នា គេនិយមប្រើកិច្ចការៈនេះទាំងពីរបែបគឺ សំពះផង ចាប់ដៃគ្នាផង ។

លក្ខណៈសំពះបានអធិប្បាយរួចមកហើយ ឥឡូវនេះនឹងអធិប្បាយអំពីគំនាប់

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចាប់ដៃគ្នាតទៅទៀត ។

កិរិយាគំនាប់ចាប់ដៃគ្នានោះ មានលក្ខណៈជាសំខាន់ណាស់ គឺគេគំនាប់គោរពគ្នាដោយចាប់ដៃស្តាំ នឹងដៃស្តាំ ព្រោះគំនាប់ចាប់ដៃនេះដែលកើតឡើងដំបូងនៅបស្ចិមប្រទេស គេចាប់ដៃគ្នាវេលាណាគេជួបគ្នា ដែលគេស្រឡាញ់គ្នា ទុកចិត្តស្និទស្នាលស្នេហានឹងគ្នា ហើយគេសួរសុខទុក្ខគ្នាទៅវិញទៅមក តែគេមិនចាប់យូរពេកទេ គេចាប់តែ១ភ្លែតព្រមទាំងសួរគ្នាថា "សុខជាទេ" ហើយលែងទៅវិញ ។ បើមានការត្រូវនិយាយច្រើន គេចេះតែនិយាយទៅមិនចាំបាច់ទុកដៃទាំងពីរឱ្យនៅជាប់គ្នាឡើយ ។ នៅក្នុងឱកាសប្រជុំគ្នាក្តី បុណ្យអ្វីក្នុង១ថ្ងៃក្តី បើបានជួបគ្នាម្តងហើយគំនាប់ចាប់ដៃគ្នាហើយៗបែកគ្នាទៅទីដទៃៗរៀងខ្លួនទៅ គ្រាដែលមកជួបគ្នាម្តងទៀតមិនបាច់ចាប់ដៃគោរពគ្នាទៀតទេ លុះគ្រាតែត្រូវលាគ្នាទៅទីលំនៅរៀងខ្លួនទើបត្រូវចាប់ដៃម្តងទៀត ជាកិច្ចគំនាប់គោរពលាគ្នា ។

គេចាប់ដៃគំនាប់តែគេស្គាល់គ្នា បើពុំនោះសោតមានអ្នកណាមួយនៅក្នុងទីប្រជុំនាំអ្នកមិនស្គាល់ឱ្យស្គាល់គ្នាឡើង ដោយមង្ហាញមុខ និងប្រាប់នាម, ត្រកូល, របររកស៊ីឬសក្តិយសថា "នេះលោក ... ធ្វើការជា ..." យ៉ាងនេះឡើងជាដំបូង ទើបជនដែលមិនស្គាល់គ្នានោះទទួលស្គាល់គ្នាភ្លាមដោយរីករាយ ហើយហុចដៃស្តាំចាប់គោរពគ្នាទៅវិញទៅមក ។

កិរិយាដែលនឹងចាប់ដៃគ្នានោះ ក្មេង[១] ក្មេងមិនត្រូវហុចដៃទៅចាប់មុនទេ

---

(១) ក្មេងគឺមានអាយុតិចជាង ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

រាស្ត្រមិនត្រូវហុចដៃទៅក្សត្រិយ៍មុនទេ សាបញ្ញជនមិនត្រូវហុចដៃទៅមន្ត្រីមុនទេ ប្រុសមិនត្រូវហុចដៃទៅស្រីមុនទេ ។

បើជួបប្រទះប៉ះមុខហើយ ក្មេងក្តី រាស្ត្រក្តី ជនសាបញ្ញក្តី ប្រុសក្តី ត្រូវតែឈរទើបជើង ហើយងក់ក្បាល បន្ទន់ខ្លួនឱនទៅមុខបន្តិចគោរពសិន ចាំឱ្យចាស់ ឬក្សត្រិយ៍ មន្ត្រី ស្រីនោះៗ ហុចដៃមកសិនសឹមទទួលទៅវិញ ទើបជាការគោរពគួរសមរៀបរយល្អ ។

តែយើងទាំងអស់គ្នា មិនត្រូវដើរទៅកេះគ្នា ហើយចាប់ដៃគ្នាទេ បើចង់គោរពគ្នា ត្រូវដើរទៅឱ្យចំពីមុខងក់ក្បាលឱ្យឃើញគ្នាសិន សឹមគំនាប់ចាប់ដៃគ្នា ។

កិរិយាដែលនឹងចាប់ដៃគ្នានោះ មិនត្រូវច្របាច់ឱ្យឈឺទេ ត្រូវចាប់ដោយទន់ភ្លន់ត្រូវចាប់ឱ្យពេញដៃទៅវិញទៅមក ព្រោះបើម្នាក់ចាប់តែត្រឹមចុងដៃ ទុកជាមានចិត្តមិនស្មោះនឹងអ្នកមួយនោះ ។ ចាប់ហើយត្រូវលែងឱ្យស្រួលទៅវិញ កុំរលាស់ ឬ កញ្ឆក់ទាញចេញមក ។

អ្នកណាមួយដែលយើងមិនស្គាល់តែគេស្គាល់អ្នកដែលនៅជិតយើងគេគំនាប់គោរពចាប់ដៃគ្នានោះ គេគិតថា ត្រូវការគួរសមនឹងយើងផង នោះបើគេគោរពយើងដោយងក់ក្បាលយើងក៏ត្រូវងក់តបទៅវិញ បើគេញញឹមមកក៏ត្រូវញញឹមតបទៅវិញ បើគេ ហុចដៃមកយើងៗគប្បីតែហុចដៃទៅចាប់វិញ ។ កុំប្រុចដៃឆ្វេងទោះតេ លើកតែដៃស្តាំយើងឈឺ ឬក់រើកមិនរួច ។

កាលណាគេរលឹកនឹកគ្នាពេកណាស់ គេចាប់ដៃគ្នាសួរសុខទុក្ខមិនហួសពី ២ ឬ ៣

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

វិនាទីទេ ។

គេចាប់ដៃគ្នា គេមិនលើកកែងដៃឱ្យស្មើនឹងស្មា ឬ ចុងដៃឱ្យខ្ពស់ឡើងកំពស់ចុងច្រមុះទេ ។ ត្រូវតែទំលាក់ដៃសំយុងឱ្យល្មមសមគួរ ។

កាលកំពុងចាប់ដៃគ្នា ត្រូវមើលមុខគ្នាឱ្យត្រង់ទៅត្រង់មក ដើម្បីសំដែងទឹកចិត្តមេត្រីស្មោះ ។

បើដៃយើងពុំស្អាត មានប្រឡាក់ដោយវត្ថុស្មោកគ្រោកមិនគប្បីនឹងហុចទៅទទួលចាប់លោកអ្នកដែលហុចដៃមក នោះត្រូវបង្ហាញដៃយើង ហើយសូមទោសថា ដៃខ្ញុំពុំស្អាត យ៉ាងនេះទើបគួរសម ។ មិនត្រូវគិតខ្លាចថា ឥឡូវលោកអ្នកធំហុចដៃមកហើយ យើងត្រូវតែទទួលកុំខានឡើយ ថ្វីបើដៃក្រខ្វក់ យ៉ាងនេះត្រឡប់ជាអំពើមិនគោរពទៅវិញ ។

## ~ប្រគេន~ថ្វាយ~ជូន~

ពាក្យថា "ប្រគេន. ថ្វាយ. ជូន" ទាំង ៣ម៉ាត់នេះមានន័យដូចគ្នា តែមានកិរិយាផ្សេងគ្នា គឺបានសេចក្តីថា "ឱ្យ" ។ គឺ "ឱ្យ" ដោយវាចារ និងឱ្យដោយកាយ ។

វត្ថុឯណាដែលលើកមិនរួច ត្រូវប្រើតែវាចាថាប្រគេន. ថ្វាយ. ជូន ទុកជាស្រេចបរិបូរណ៍ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នឹងអធិប្បាយពីកិរិយាលើកប្រគល់ឱ្យដល់ដៃ ។

"ប្រគេន" និយាយអំពីកិរិយាលើកវត្ថុផ្សេងៗប្រគេនដល់ព្រះហស្តព្រះភិក្ខុសង្ឃ អោយត្រឹមត្រូវដល់ហត្ថបាស ។

"ថ្វាយ" (ពាក្យរាជសព្ទ) និយាយត្រង់លើកវត្ថុផ្សេងៗថ្វាយដល់ក្សត្រិយ៍ ។

"ជូន" ប្រើត្រង់លើកវត្ថុផ្សេងៗជូនដល់ដៃបុព្វការី, គ្រូអាចារ្យ, មន្ត្រី, ចាស់ព្រឹទ្ធាចារ្យ ឬ បុគ្គលណាមួយ ដែលយើងត្រូវគោរព ។

កិរិយាប្រគេនក្តី, ថ្វាយក្តី, ជូនក្តី, ត្រូវប្រកាន់របស់ដែលនឹងលើកប្រគេនថ្វាយជូនទៅនោះ ដោយដៃទាំងពីរទើបពេញលក្ខណៈ នៃគារវកិច្ច ។ ចុះបើកាន់តែដៃ១វិញ នោះមិនគួរ គេឱ្យឈ្មោះថា "ហុច" ទៅវិញ ។

## ~ហុច~

"ហុច" គឺឱ្យដោយដៃតែម្ខាងប្រយោល ។ ដូច្នេះកិរិយាដែល "ប្រគេនក្តី, ថ្វាយក្តី, ជូនក្តី" មិនត្រូវហុចឱ្យសោះ ។ តែប្រសិនបើយើងមានវត្ថុអ្វីមួយ ត្រូវប្រើដៃស្តាំកាន់ឱ្យជាប់ នឹងដាក់ចោលមិនបាន ឬ នឹងលែងឱ្យឃ្លាតពីដៃមិនបាន គប្បីប្រើកាន់វត្ថុនោះនឹងដៃឆ្វេងហើយកាន់របស់ដែលត្រូវហុចនោះនឹងដៃស្តាំ ទើបរាប់បញ្ចូលទៅក្នុងការគោរពបានដែរ ដោយសន្មោសអធ្យាស្រ័យថាដៃឆ្វេងជាប់រវល់ ដៃស្តាំរាប់យកជា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ទីគោរពបាន ។ យើង "ហុច" បានតែអ្នកមានយសសក្តិស្មើគ្នា ឬមួយអ្នកធំ ហុចឱ្យទៅអ្នកតូច ។

កាន់របស់ដែលមានដង, មានផ្លែមុត, មានចុងស្រួច, កាន់ភ្លើង ... ។ល។

ទោះនឹងប្រគេន, ថ្វាយ, ជូន, ហុច របស់ដែលមានដង, មានផ្លែមុត, មានចុងស្រួច, ត្រូវកាន់បង្វិលដងទៅខាងអ្នកទទួល មុខដែលមុត, ស្រួចមកខាងយើង ។

ប្រៀបដូចកាំបិត, ដងប៉ាកកា, អំបោស, ... ។ល។ នោះត្រូវបង្វិលមុខកាំបិត, ចុងស្លាបប៉ាកកា, ចុងអំបោស, មកខាងយើងដែលជាអ្នកប្រគេន, អ្នកថ្វាយ, អ្នកជូន, អ្នកហុច ។ បើជាកន្ទុយអុសដែលមានភ្លើង ឬជាកន្ទុយបារីដែលកំពុងឆេះនោះ ក៏ត្រូវបង្វិលខាងភ្លើងមកខាងខ្លួនយើងសិនសឹមប្រគេន, ថ្វាយ, ជូន, ហុច ខាងដែលឥតភ្លើងនោះទៅ ។

## របស់ដែលនឹងយកទៅប្រគេនលោកសង្ឃ ថ្វាយក្សត្រិយ៍ ជូនបុព្វការី ឬចៅហ្វាយនាយ ឬចាស់ព្រឹទ្ធាចារ្យ ។

របស់ឯណាដែលយើងចាត់ចែង នឹងយកទៅនោះ គប្បីរកភាជន៍ ដ៏សមល្មមមកដម្កល់១ជាន់ទៀត ទើបសមគួរ ។

ប្រៀបដូចយើងចង់យកម្ហូបចំណើទៅប្រគេនព្រះសង្ឃ ។ ម្ហូបចំណីទាំងនោះ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដាក់ក្នុងភាជនៈកែវ ឬ ចានរួចទៅហើយ តែត្រូវឱ្យមានជើងពាន ឬថាស១ទ្រភាជនៈ ដែលដាក់ម្ហូបចំណីនោះទៀត ទើបគ្រប់បរិបូរណ៍ក្នុងការគោរព ។

ទោះជាថ្វាយក្សត្រិយ៍ក្ដី ជូនមាតាបិតាគ្រូអាចារ្យក្ដី... ។ល។ គប្បីតែរៀបចំឱ្យប្រសើរ ដូចយ៉ាងរបៀបរាយបកនេះ ។

ដូចដង្វាយដែលនាំយកទៅថ្វាយក្សត្រិយ៍ខត្តិយត្រកូល អ្នកមានទ្រព្យគេច្រើនប្រើដីកល់លើថាសមាសប្រាក់ ដើម្បីឱ្យលើកតំលៃនៃដង្វាយនោះៗ ចំពោះរូបមួយ ។

បើជាចំពោះច្រើនរូបវិញនោះ ត្រូវប្រើរបៀបដែលងាយ រហ័ស តែនៅក្នុងការគោរពជាដរាប ។

ឧបមាដូចប្រគេនទឹកតែដល់ព្រះសង្ឃច្រើនអង្គ ឬជូនទឹកក្រូចឧបាសកច្រើននាក់ ។ ទឹកតែដាក់ក្នុងពែងតែ ពែងនោះគ្មានចានទ្រ ទឹកក្រូចដាក់ក្នុងកែវ កែវនោះគ្មានចានទ្រ តែត្រូវដម្កល់ពែងតែនិងកែវទឹកក្រូច ដាក់លើថាស ១ធំ ចំនួនច្រើនពែង ច្រើនកែវ ។

យើងលើកទៅទាំងថាស កិច្ចដែលនឹងប្រគេនលោក ត្រូវចូលទៅជិតហើយនិមន្តលោកឱ្យចាប់យក ១អង្គ ១ពែង ឬ ២ ពែងតាមគួរ យ៉ាងនេះទើបត្រូវតាមក្បួនអនាម័យ (បើជូនភ្ញៀវក៏ដូចគ្នា) ។

<u>សូមកុំភ្លេច</u> : យើងមិនត្រូវចាប់ពែងតែ ឬ កែវទឹកប្រគេន ថ្វាយ. ជូន ទៅឱ្យសោះឡើយ ដើម្បីកុំឱ្យមានរង្កៀសចិត្តថា ដៃយើងតើស្អាត ឬមិនស្អាត ។

មានកាលលោកអ្នកត្រូវការភេសជ្ជៈ ដោយប្រញាប់ប្រញាល់ពេក យើងលើក

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ជូន ១កែវទៅ តែមិនត្រូវកាន់មាត់កែវនោះឱ្យសោះ ឬច្រមពីលើ ត្រូវទ្រកែវនោះឱ្យនៅពីលើបាតដៃ ឬក៏ចាប់កាន់ខាងបាតកែវ ទើបរួចពីសេចក្ដីសង្ស័យ នឹងដៃស្អាតឬមិនស្អាត ។

នៅឱកាសប្រជុំម្ដងៗ ហើយមានវរជនជាអធិបតី ដូចជាសម្ដេចព្រះសង្ឃនាយក ឬព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។ល។ បើយើងប្រគេន ឬថ្វាយភេសជ្ជៈ ត្រូវដម្កល់វត្ថុនោះឱ្យសមរម្យ ឱ្យដាច់ឡែកអំពីក្បៀវសាមញ្ញ មិនត្រូវធ្វើឱ្យខុសទើបគួរ ។

## ~និយាយ~

និយាយជាកិរិយាដែលបញ្ចេញសំដី ពោលពាក្យល្អ ពីរោះផ្អែមពីសា ឬអាក្រក់ទ្រគោះបោះបោក ខ្លាំងតិចខ្សឹបខ្សៀវ ... ។ល។

កិរិយាដែលនឹងនិយាយស្ដី មានច្រើនលក្ខណៈណាស់ ដូច្នេះបើយើងនឹងនិយាយស្ដីត្រូវគិតឱ្យស្រេចសឹមនិយាយ ។ បុរាណលោកចងជាពាក្យប្រដៅទុកមកថា "សំដីជាឯក - លេខជាទោ" ។

នេះបានសេចក្ដីថា ពាក្យសំដីដែលចេញពីមាត់ទៅហើយ អាចនឹងនាំឱ្យមានផលប្រយោជន៍ក៏មាន មានកាលបើនិយាយទៅហើយពានទៅលើខុសនុ៎ះ នឹងឱ្យខូចផលប្រយោជន៍ក៏មាន ។ យ៉ាងនេះហើយ ទើបលោករាប់ថា "សំដីជាឯក" ។

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

"ឯលេខជាទោ" នោះមានន័យថា ការសរសេរឬគិតបូកបោះជាការបន្ទាប់សន្សំទេ ព្រោះការសរសេរជាសេចក្តីតេព្រាងសិន តែអាចនឹងកែសេចក្តីព្រាងនោះម្តង ឬពីរបីដងទៀតក៏បាន បើត្រឡប់ជាខុសខូចទៅវិញក៏លុបបរសំចិត្ត ដោយការគិតមិនដល់ ។ ឯពាក្យសំដីនិយាយតែជ្រុលជ្រលូសខុសទៅហើយ ពិបាកនឹងកែណាស់ ។ សមនឹងពាក្យចាស់ថា "រនាបបាក់យករនាបជួស តែសំដីហួសគ្មានអ្វីជួសបាន" មិនតែប៉ុណ្ណោះទេ លោកពោល១ម៉ាត់ទៀតថា "បនុស្សគេយកសំដី ដំរីគេយកភ្លុក" នេះមានន័យថា សំដីមនុស្សនេះតែនិយាយចេញពីមាត់ទៅហើយ គង់អ្នកដទៃឮស្តាប់បានថានិយាយល្អ ឬ អាក្រក់ មិនដែលសំដីនេះលើបចូលបាត់ទៅក្នុងមាត់វិញទេ ប្រៀបដូចជាភ្លុកដំរី ដែលដុះចេញពីមាត់វាមកហើយ មិនដែលលើបចូលទៅក្នុងមាត់វាបានវិញទេ ។

បានជាលោកទុកសំដីនេះ ដូចភ្លុកដំរី ។

លោកប្រៀបមួយម៉ាត់ទៀតថា " អណ្តាតជាអាទិ៍កន្លង សុខ-ទុក្ខ-ទោសផងកើតពីអណ្តាត"។

បានសេចក្តីថា ពាក្យសំដីដែលចេញពីមាត់ រមែងឱ្យសុខ និងទុក្ខទោសដល់អ្នកនិយាយ ។ ហេតុនេះហើយ លោកប្រដៅថា ត្រូវពិតឱ្យមែនទែនមុននឹងនិយាយ ត្រូវនិយាយឱ្យត្រឹមត្រូវ ត្រូវនិយាយដោយសុភាព និយាយដោយបញ្ញាពិចារណាអោយឃើញពិត ឃើញមែន ដល់ត្រចៀកអ្នកស្តាប់ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# ~របៀបនិយាយ~

និយាយមានច្រើនបែបផែន មានជាច្បាប់ក្បួនដែលបុរាណលោកចងទុកបក ។ របៀបនិយាយ និងរបៀបសរសេរ ពុំបានជាប្លែកគ្នាប៉ុន្មានទេ ខុសគ្នាត្រង់តិចបន្តួច ដោយសារតែរបៀបនិយាយច្រើនប្រើដំណើរកាត់ប្រួតឱ្យខ្លីៗប៉ុណ្ណោះ ។

១- និយាយនឹងព្រះសង្ឃ ជារបៀប១ដោយឡែកដែលយើងរាល់គ្នាចេះចាំហើយ ។

២- និយាយនឹងក្សត្រិយ៍ខត្តិយត្រកូល នេះត្រូវរៀនតាមក្បួនរាជសព្ទ ព្រោះក្សត្រិយ៍មានច្រើនថ្នាក់ ហើយមានរបៀបនិយាយតាមឋានន្តរសក្តិ ។

និយាយនឹងព្រះមហាក្សត្រិយ៍ទ្រង់រាជ ១

- ក្សត្រិយ៍ជាន់ខ្ពស់ គឺស្តេចតាំងក្រុម ១
- ក្សត្រិយ៍ ទីព្រះអង្គម្ចាស់ ១

និយាយនឹងក្សត្រិយ៍ទីអ្នកអង្គម្ចាស់ ១

ទីអ្នកអង្គ ១

ត្រង់នេះ យើងត្រូវឱ្យចេះឱ្យស្ទាត់នូវពាក្យដែលមានក្នុង "ក្បួនរាជសព្ទ" ។ បើឯការសរសេរវិញត្រូវអាស្រ័យក្បួន "ប្រជុំពិធិខិត" ជាគំរូ ។

៣- និយាយនឹងមន្ត្រីធំ-តូច ដែលលោកមានយសសក្តិជាលោកអាមាត្រគឺជារដ្ឋមន្ត្រី ឧត្តមមន្ត្រី វរមន្ត្រី អនុមន្ត្រី ... ។ល។ ចាងហ្វាង និង ចៅក្រប ... ។ល។ ប៉ុណ្ណោះជាដើម នោះយើងគប្បីរៀនតាមទំរង់សក្តិ ដែលរៀបចំជារបៀបសរសេរក្នុង

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក្សូន "ប្រជុំលិខិត" ។

សូមរំលឹកថា ការនិយាយនេះមិនត្រូវឱ្យស៊ុនខ្ពស់ទាប ប្អូសប្រមាណឡើយ ។ ត្រូវគិតថ្នាក់របស់ខ្លួនសិនសឹមគិតដល់យសសក្តិលោកណាដែលយើងនិយាយផង ។

នឹងធ្វើឧទាហរណ៍បន្តិច ដើម្បីបំភ្លឺក្នុងរបៀបនិយាយគោរពចំពោះមន្ត្រី ។ ដូចជាពាក្យថា "បាទ. ខ្ញុំបាទ. ខ្ញុំប្របាទ. ខ្ញុំប្របាទម្ចាស់" ។

នេះត្រូវចាំថា :

| | | |
|---|---|---|
| ស្មើសក្តិគ្នា | ត្រូវឆ្លើយ | បាទ |
| តូចជាង ១ ទៅ ២សក្តិ | - | ខ្ញុំបាទ |
| តូចជាង ៣ សក្តិ | - | ខ្ញុំប្របាទ |
| តូចជាង ៤ ដល់ ៧សក្តិ | - | ខ្ញុំប្របាទម្ចាស់ |
| រាស្ត្រឆ្លើយរដ្ឋមន្ត្រី | - | ខ្ញុំប្របាទម្ចាស់ជាដរាប |
| ចំណែកស្រីៗវិញ | - | បណ្ឌាភរិយាមន្ត្រីមានឋានន្តរសក្តិហៅថា: |

១- ជំទាវ

២- លោកស្រី

៣- អ្នកស្រី

## ជំទាវ

ដែលនឹងហៅបានថា "ជំទាវ" លុះត្រាតែភរិយាពេញច្បាប់នៃរដ្ឋមន្ត្រី (សេនាបតី) ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ព្រះមេត្តាប្រោសតាំងដោយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ព្រះរាជប្រកាស ឬ ព្រះរាជក្រិត្យ ។ បើពុំដូច្នោះទេបណ្ដាភរិយាមន្ត្រីជាន់ខ្ពស់ ស្វាមីមានយស ១០. ៩. ៨. ៧ ហ៊ូពាន់ ត្រូវហៅបានត្រឹមលោកស្រី ព្រោះស្វាមីទីជាឧកញ៉ា តែត្រូវចែកជាពួក១ៗទៅទៀត ។

## លោកស្រី

១- ស្វាមីមានសក្តិ ១០ ហ៊ូពាន់ ទីលោកអ្នកឧកញ៉ា ភរិយាត្រូវជា "លោកស្រី" ជាន់ឯក (ដើមខ្សែ) ។

២- ស្វាមីមានសក្តិ ៩ ហ៊ូពាន់ ទីអ្នកឧកញ៉ា ភរិយាត្រូវជា "លោកស្រី" ជាន់ទោ (បន្ទាប់) ។

៣- ស្វាមីមានសក្តិ ៨ ហ៊ូពាន់ ទីឧកញ៉ា ភរិយាត្រូវជា "លោកស្រី" ជាន់ត្រី (ទី៣) ។

៤- ស្វាមីមានសក្តិ ៧ ហ៊ូពាន់ ទីឧកញ៉ាដែរ ភរិយាត្រូវជា "លោកស្រី" ជាន់ចត្វា (ទី ៤) ។

## អ្នកស្រី

១- ស្វាមីមានសក្តិ ៦ ហ៊ូពាន់ ទី "ព្រះ" ភរិយាត្រូវហៅថា "អ្នកស្រី" ជាន់ឯក (ដើមខ្សែ) ។

២- ស្វាមីមានសក្តិ ៥ ហ៊ូពាន់ ទី "ហ្លួង" ភរិយាត្រូវហៅថា "អ្នកស្រី" ជាន់ទោ (បន្ទាប់) ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

៣- ស្វាមីមានសក្តិ ៤ ហ៊ូពាន់ ទី "ឃុន" ភរិយាត្រូវហៅថា "អ្នកស្រី" ជាន់ត្រី (ទី ៣) ។

៤- ស្វាមីមានសក្តិ ៣ ហ៊ូពាន់ ទី "ប៊ុន" ភរិយាត្រូវហៅថា "អ្នកស្រី" ជាន់ចត្វា (ទី ៤) ។

ឯរាស្ត្រសាមញ្ញត្រូវហៅថា "អ្នក" ក៏ជាការល្មមសមគួរហើយ ។



## ចៅជីត-ចៅចម

បណ្តាស្ត្រីជាព្រះស្នំព្រះមហាក្សត្រិយ៍ ស្តេចផែនដី ត្រូវបានយសជាលំដាប់ ហៅថា ឃុន, ម៉ម, អ្នកម្នាង, អ្នកនាង, ដែលព្រះរាជាទ្រង់ព្រះមេត្តាប្រោសលើកឡើងដោយព្រះរាជទានឡាយ ព្រះរាជហត្ថលេខាក្នុងសញ្ញាប័ត្រជាសំគាល់ នោះត្រូវគោរពពេញទីជាព្រះស្នំម្ចាស់ផែនដី ។

ការនិយាយស្តីពិនត្រូវហៅថា ជំទាវ, លោកស្រី, អ្នកស្រី ឬអ្នកទេ ត្រូវហៅថា ឃុន, ម៉ម, អ្នកម្នាង, អ្នកនាង យ៉ាងនេះ ទើបត្រូវ ។



www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ~និយាយក្នុងទីប្រជុំ~

និយាយក្នុងទីប្រជុំ ត្រូវប្រើពាក្យសំដីពីរោះផ្អែមពិសា ប្រើពាក្យគោរពឱ្យត្រឹមត្រូវតាមទំរង់សក្តិ តាមថ្នាក់តាមជាន់ គួរសមនឹងគ្នាទៅវិញទៅមក តាមសណ្តាប់ប្រវេណី គឺថាឱ្យស្គាល់បព្វជិត និងគ្រហស្ថ.

ឱ្យស្គាល់ក្សត្រិយ៍ និង បព្វជិត

ឱ្យស្គាល់ក្សត្រិយ៍ និង ប្រជារាស្ត្រ

ឱ្យស្គាល់ក្សត្រិយ៍ និង មន្ត្រីធំ - តូច

ឱ្យស្គាល់មន្ត្រី និង ប្រជារាស្ត្រ

ឱ្យស្គាល់ប្រជារាស្ត្រ និង ប្រជារាស្ត្រ

ឱ្យស្គាល់ចាស់ និង ក្មេង

ឱ្យស្គាល់ស្ត្រី និង បុរស

ឱ្យស្គាល់មាតា - បិតា និង កូន

ឱ្យស្គាល់ជីដូន ជីតា និង ចៅ

ឱ្យស្គាល់ចៅហ្វាយនាយ និង អ្នកបំរើ

ឱ្យស្គាល់ឪពុកធំ មីង មា និង ក្មួយ ។ល។

ដំណើរនិយាយកាន់គ្នាទៅវិញទៅមកប្រកបបរិបូរណ៍ដោយគារវកិច្ចក្នុងវោហាហើយការចរចារនោះសោតពិរោះ រៀបរយល្អតល្អាយសប្បាយទាំងអស់គ្នា ។

នរណាហើយ មិនចេះប្រកបពាក្យសំដីពីរោះល្អ ប្រើតែពាក្យថោកទាប ពាក្យ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ពាក្យគ្រោះបោកបោះ ពាក្យអសុរស ពាក្យចាក់ដោត ហាក់ដូចជាថ្នាំពុល អ្នកនោះ រមែងបណ្ដាលនូវសេចក្ដីក្ដៅក្រហាយ សេចក្ដីក្រោធខឹងនឹងសេចក្ដីជំលោះដល់អ្នក ដែលបានឮបានស្ដាប់ ដោយទទួលនូវរសជាតិនៃពាក្យស្លែងនោះ ។

# ទីប្រជុំមានច្រើនយ៉ាង

ក- ប្រជុំស្ដាប់ធម៌ទេសនា ឬ សូត្របន្ត

ប្រជុំស្ដាប់សុន្ទរកថា

ប្រជុំស្ដាប់សន្និសិទ

ប្រជុំស្ដាប់ច្រៀង

ប្រជុំមើលកុនស្រមោល

ប្រជុំទាំង ៥ នេះ មានតែ ១នាក់និយាយ ឬ ពីរនាក់និយាយឆ្លើយឆ្លងគ្នា ដោះបញ្ហាផ្សេងៗ ។ ដូច្នេះអ្នកដែលចូលទៅសន្និបាទប្រជុំនោះៗ ត្រូវប្រកាន់ កិរិយា សុភាពរៀបរយដោយគោរពដល់អ្នកសំដែង គឺមិននិយាយ ឬខ្សឹបគ្នាឱ្យឮសំលេង ១ឡើងទៀត ឱ្យរំខានដល់អ្នកទាំងឡាយ ដែលគេប្រាថ្នានឹងស្ដាប់យកជាការផង ។ មិនតែប៉ុណ្ណោះឡើយ លោកអ្នកសំដែង រមែងកើតបដិឃៈ ចង្អៀតចង្អល់ ខ្វល់ចិត្ត ដ្បិតអ្នកស្ដាប់សំដែងអាកប្បកិរិយាមិនពេញចិត្តនឹងស្ដាប់ ដូច្នេះគប្បីតែនាំគ្នា

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដើរចេញពីទីនោះឱ្យផុតទៅ សឹមនិយាយគ្នាតាមអំពើចិត្តខ្លួន ទើបសមជាអ្នកស្គាល់កាល និងកិច្ចគេឯងរាល់គ្នា ។

ប្រៀបដូចស្ដាប់ធម៌ទេសនា ជាសេចក្ដីបដិបត្តិ១ ដ៏សំខាន់ក្រៃលែង សំរាប់អ្នកកាន់សាសនា ។ តែកាលហោគេចូលទៅកាន់ព្រះវិហារក្ដី សាលាក្ដី រោងឆទានក្ដី ឬក្នុងគេហដ្ឋានឯណានីមួយក្ដី ដែលគេនិមន្តធម្មកថិកមកសំដែងធម៌ទេសនា នោះយើងអ្នកស្ដាប់មិនត្រូវនិយាយឱ្យឮអ៊ូអរសោះឡើយ មិនត្រូវយកកូនចៅទៅផង ហើយបណ្ដែតបណ្ដោយឱ្យប្រឡូកប្រឡែងគ្នាឮសូរសាព្ទស្រែកទ្រហឹងអឹងកង ឱ្យរំខានដល់ចាស់ទុំដែលកំពុងប្រុងស្មារតីត្រងចងចាប់យកនូវមធុរសនៃធម៌ទេសនានោះៗ ។

ខ- ប្រជុំរបស់សមាគម

ដំណើរប្រជុំរបស់សមាគមនីមួយ១ នោះតែងតែមានគណៈកម្មាធិការនាយកជាធំ មានប្រធាន - អនុប្រធាន - អគ្គលេខាធិការ ... ។ល។ ជាអ្នកចាត់ការបើកឱកាសនិយាយពិគ្រោះពីការផ្សេង១ តាមរបៀបវារៈ ។

នេះបណ្ដាសមាជិកដែលទៅប្រជុំផង មិនត្រូវដណ្ដើបគ្នានិយាយ ជជែកស្រែកគំហកកំហែងគ្នាឯងទេ ឱ្យកើតជាជំលោះបានឡើយ ។ ត្រូវតែស្ដាប់គ្នា ហើយនិយាយជជែកតវ៉ា តាមលំដាប់ម្ដង១ម្នាក់ មិនត្រូវនិយាយកាត់គ្នាឱ្យខូចសេចក្ដីអធិប្បាយរបស់អ្នក១ដែលកំពុងនិយាយបរិយាយពន្យល់អោយឃើញហេតុឃើញផលឡើយ ។ ត្រង់នេះត្រូវដឹងថាមានតែប្រធាន១ទេ ដែលមានសិទ្ធិនឹងឃាត់ហាមអ្នកនិយាយឱ្យឈប់បាន ដោយយល់ថា និយាយវែងពេកមិនបានការ ឬនិយាយគ្មានចុងគ្មានដើម

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចេញក្រៅរឿងដែលគេគោលទុករវោយនិយាយ ។

## -និយាយលេង-

ដំណើរនិយាយលេងជាល្បែងគ្រហាច់សើចលេងនោះ ត្រូវវាងពាក្យចំអេសចំអាស ។ ត្រូវវាំងប្រែងពេលស្រីញី ឬ ប្រុសឈ្មោលចូលមកជិតទីប្រជុំនោះ មិនសមនឹងឱ្យឮនូវពាក្យសំដីដែលយើងនិយាយគ្នាជាមិត្រស្និទ្ធ ។ ពិតមែនតែយើងជាមិត្រនឹងគ្នា ប៉ុន្តែអ្នកដែលនៅជុំវិញយើង គេពុំរីករាយសប្បាយដោយពាក្យសំដីដែលជាអាស្រូវអប្រិយដល់ត្រចៀកគេឡើយ ម្លោះហើយគេរមែងតែងតែតេះដៀលដល់យើងថាជាមនុស្សមិនស្គាល់ខុសត្រូវពោលពាក្យអាស្រូវនៅមុខគេ ។

ឯដំណើរនិយាយលេងសើចនេះ បានឥតទាស់តែនៅទីដទៃក្រៅពីគេហដ្ឋានដែលគេគ្មានទុក្ខ ។ បើយើងទៅសួរសួរសមនឹងញាតិមិត្រ ដែលកំពុងមានទុក្ខដោយព្រាត់ប្រាសគ្នាស្លាប់រស់យ៉ាងណាក្តី មានជំងឺឈឺចាប់ជាទម្ងន់ក្តី មានធុរៈដោយលង់ទូកក្តី ដោយភ្លើងឆេះផ្ទះក្តី យើងកុំពប្បើនិយាយលេងសើចឱ្យសោះ ត្រូវសង្រួមកាយវាចាឱ្យស្រគត់ស្រគំឱ្យសមជាអ្នកជួយទទួលទុក្ខជាមួយនឹងក្រុមញាតិគេដែរ ។

បើប្រសិនណាជាយើងទៅហែរសពតាមផ្លូវក្តី នៅទីប៉ាឆាក្តី យើងមានការនិយាយនឹងអ្នកណាមួយដោយខានពុំបាន ក៏ត្រូវនិយាយខ្សឹប១កុំឱ្យឮលាន់ពាក្យសំដី

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ឱ្យភ្ញាក់ផ្អើលដល់អ្នកដែលនៅផងគ្នាក្នុងទីនោះ ។ នេះជាការកិច្ច ១ យ៉ាងសំខាន់ដែលយើងរាល់គ្នាគប្បីបំពេញឱ្យបរិបូរណ៍ ព្រោះនៅពេលដែលយើងទៅបុណ្យខ្មោចនេះ យើងត្រូវតែមានធម៌សង្វេគរឭកឃើញដល់អាយុសង្ខារនៃយើងគ្រប់ៗគ្នា ។

## ~និយាយខ្សឹប~

ដំណើរនិយាយខ្សឹបនេះ គឺនិយាយតិចៗជិតត្រចៀកគ្នា ដើម្បីកុំអោយអ្នកដទៃដែលនៅជិតខាងឮផងបាន ។

និយាយខ្សឹបនេះ មានកាលត្រូវតែខ្សឹបទើបគួរ មានកាលខ្សឹបទៅជាហេតុអាក្រក់នាំឱ្យខូចការងារផ្សេងៗ ។ ដូច្នេះ យើងត្រូវឱ្យដឹងនូវកាលដែលនឹងត្រូវខ្សឹបនឹងមិនត្រូវខ្សឹប ។

## ត្រូវនិយាយខ្សឹប

១- នៅពេលដែលអ្នកនៅជិតខាងយើងនៅក្នុងបន្ទប់ជាមួយក្ដី បន្ទប់ជាប់គ្នាក្ដីនោះយើងត្រូវនិយាយខ្សឹប នៅពេលដែលគេដេកយប់ ថ្ងៃ កុំឱ្យគេរំខានក្នុងដំណើរដែលគេសំរាកកំលាំង ។

២- យើងទៅសួរគួរសមនឹងញាតិមិត្រ ដែលមានជម្ងឺដំកាត់ ហើយត្រូវការតែ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ស្ងាត់ គេចរអំពីកង្វល់ផ្សេងៗ ត្រូវការតែសំងំផ្ទុំស្មារតី ឱ្យស្ងប់រំងាប់ប្រាស់ចាក ការចង្អៀតចង្អល់ខ្វល់ចិត្ត ។ ដូច្នេះគប្បីជៀសវាង សេចក្តីមិនគាប់ចិត្តអ្នកជម្ងឺ ដើម្បីជួយផ្ទុំមចិត្តអ្នកជម្ងឺ នោះបណ្តាអ្នកទៅសួរសុខទុក្ខសួរសមដោយមេត្រី ត្រូវនិយាយស្តីឱ្យពីរោះហើយខ្សឹបៗផងទើបគួរ ។ តែបានកាលខ្លះយើងអាចនឹងនិយាយលេងបន្តិចបន្តួចបាននឹងអ្នកជម្ងឺដែលមានរោគស្រាល ជាការលួងលោមឱ្យបានអ្នកជម្ងឺនោះសប្បាយរីករាយចិត្ត ជាប្រយោជន៍ឱ្យបានឆាប់ជាស្បើយល្ហើយរំពីជម្ងឺដែកាត់នោះក៏សឹងមានដែរ ។

តែបើលោកគ្រូពេទ្យហាមមិនឱ្យអ្នកជម្ងឺនិយាយសោះ ខ្លាចក្រែងរោគកំរើកខ្លាំងឡើង ដោយអ្នកជម្ងឺប្រឹងនិយាយ ដូច្នេះយើងត្រូវប្រតិបត្តិ គោរពតាមបំរាមពេទ្យ ។

៣- ក្នុងក្បួនហែសព យើងត្រូវនិយាយខ្សឹបជាដរាបតាំងពីផ្ទះរហូតដល់ទីប៉ាឆាទាំងប្រើកិរិយាស្រគត់ស្រគំទៀតផង ។ បើប្រសិនលោកអ្នកដែលប្រកបនូវសង្វេគធម៌ពិចារណាពីដំណើរជីវិតដែលត្រាច់រង្គាត់ក្នុងវដ្តសង្សារ នោះប្រហែលជាលោកមិននិយាយសោះផង ព្រោះលោកជាប់ក្នុងព្រះកម្មដ្ឋានឯណាមួយក៏សឹងមាន ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# មិនត្រូវនិយាយខ្សឹប

ក្នុងចំណោមប្រជុំគ្នាច្រើននៃសមាគមណាមួយ ដើម្បីពិគ្រោះដោះស្រាយបញ្ហាផ្សេងៗ នោះបណ្ដាអស់លោកអ្នកជាសមាជិក គប្បីកុំប្រើកិរិយានិយាយខ្សឹបឱ្យសោះ ប្រយោជន៍ចៀសវាងនូវសេចក្ដីរង្កៀសសង្ស័យក្រែងកើតមានឡើងរវាងគ្នាឯង ។ តែសេចក្ដីរង្កៀសចិត្ត កើតមានឡើងហើយកាលណា សេចក្ដីសាមគ្គីក្នុងសមាគមនោះរមែងរលាយបាត់បាក់បែកគ្នាមិនខាននាកាលណោះ ។

កាលខ្សឹបដែលឱ្យកើតជាទោស ដូចអធិប្បាយខាងលើនេះ យើងកុំគប្បីធ្វើឱ្យសោះ ។

មួយទៀត បើយើងមានការត្រូវខ្សឹបគ្នា តែជួនជាមានអ្នកឯណាមួយដើរមកនេះត្រូវវាងកុំឱ្យគេសង្ស័យថាយើងខ្សឹបរិះគន់គេ ដូច្នេះគប្បីតែបង្អង់ខ្សឹប មួយស្របក់ ឱ្យអ្នកនោះដើរទៅហួសសិនជាការល្អ ជាការមិនឱ្យគេរង្កៀសចិត្តនឹងយើងថាយើងនិយាយចុងដើមអំពីគេ ។

ដូចពាក្យមួយឃ្លាខាងក្រោមនេះថា

"និយាយខ្សឹបឮឆ្ងាយ ដំណឹងពីចម្ងាយឮច្បាស់" ។

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

# ~មិនត្រូវនិយាយភាសាដទៃ~

ក្នុងទីប្រជុំនីមួយៗ ដែលបានសុទ្ធតែជនជាតិជាមួយគ្នា ហើយគេពិភាក្សាជជែកពិគ្រោះគ្នាអំពីការផ្សេងៗ ដោយប្រើភាសាជាតិរបស់ខ្លួន ព្រោះក្នុងទីប្រជុំនោះ បានជនខ្លះមិនចេះភាសាដទៃក្រៅពីភាសាខ្លួន ។ យើងរាល់គ្នាជាសមាជិក ឬ ជាទីប្រឹក្សាសមាគម ឬ សភានោះ ៗ កុំគប្បីប្រើភាសាដទៃនិយាយការអ្វីមួយផ្សេងនឹងសមាជិកផងគ្នា ២-៣ នាក់ដោយឡែកទៅទៀត ។ ព្រោះដំណើរប្រើភាសាដទៃនៅចំពោះមុខជនជាតិដូចគ្នា ជាហេតុនាំឱ្យអ្នកទាំងពួងនៅទីនោះ កើតរង្កៀសសៅហ្មងចិត្តគិតឡើងថាគេមានការមិនត្រង់ មានការលាក់កំបាំង មានការក្បត់គំនិត ...។ល។ សេចក្តីសង្ស័យយ៉ាងនេះកើតឡើងកាលឯណាហើយ សេចក្តីសាមគ្គីនឹងបែកខូចនាកាលណោះ ។ ដូច្នេះហើយទើបលោកហាមថា កុំឱ្យនិយាយភាសាដទៃ នៅទីប្រជុំជនជាតិដូចគ្នា ដែលមានជនខ្លះមិនចេះភាសាដទៃ ដើម្បីរក្សាសេចក្តីសាមគ្គីរួបរួមគ្នាឱ្យបានថាវរៈ មាំទាំល្អតទៅ ។

តែបើនៅទីប្រជុំនោះ បានជនជាតិបរទេសមកផងដែរ ដូចនៅពេលលៀងអាហារ លៀងភេសជ្ជៈ ជូនដំណើរមិត្រភក្តិឡើងយន្តហោះ រថយន្ត រថភ្លើង ចុះទូកកប៉ាល់ ។ល។ នោះអ្នកដែលចេះភាសាបរទេស ហើយត្រូវការរាក់ទាក់ចៅរៅដោយមេត្រីនឹងអ្នកបរទេសនោះ ។ នឹងនិយាយភាសាបរទេសបានឥតមានទាស់ឆ្គងអ្វីឡើយ ។ ការនិយាយភាសាបរទេស ទៅកាន់អ្នកបរទេស ជាប្រយោជន៍ឱ្យយើងបានចាំពាក្យសំដីនៃភាសាដទៃនោះផង ចាំបែបផែន ទម្លាប់ដែលគេនិយាយនោះផង ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

## ~និយាយចំអកឡកឡឺយ~

ដំណើរនិយាយចំអកឡកឡឺយឱ្យគេឯងរាល់គ្នា ឬចំពោះអ្នកឯណានីមួយនៅក្នុងទីប្រជុំមួយនោះ គប្បីប្រយ័ត្នឱ្យមែនទែន ខ្លាចទៅជាហេតុបង្កើតទៅជាជម្លោះឈ្លោះជេរពោលរោលពត់គ្នា ជួនកាលបណ្តាលដល់ទៅវាយតប់ ទាត់ធាក់កាប់សម្លាប់គ្នាក៏សឹងមាន ។ ពាក្យនិយាយចំអកនេះកុំថាឡើយតែអ្នកមិនស្និទ្ធស្នាល សូម្បីតែមិត្រដែលជិតដិត ចិត្ត១ ថ្លើម១ផងគ្នា នោះការនិយាយលេងជាពាក្យចំអកក៏ត្រូវតែរវាំងបុខក្រោយជាដរាប កុំឱ្យជ្រុលជ្រួសជ្រលូសទ ...តែមាស់គ្នាបាន ព្រោះពាក្យចំអករមែងធ្វើឱ្យគេអៀនអន់ស្រពន់ចិត្ត ខ្មាសមុខអ្នកដែលទៅទីប្រជុំនោះផង ។

## និយាយបន្ទោស

## និង

## រំលឹកដាស់តឿន

ក្នុងសង្គមនីមួយៗ ឬគ្រួសារ ឬ ក្រសួង ឬក្រុម ឬផ្នែក ដែលចាត់ថាពួកគណៈនោះ បណ្តាសាច់សារលោហិតក្តី បុគ្គលិកក្តី សហការីក្តី សមាជិកក្តី សិស្សានុសិស្សក្តី... ។ល។ ដែលរួមសុខទុក្ខជាមួយគ្នា រួមការងារជាមួយគ្នា រួមព័និតក់ឡាំងជាមួយគ្នា...

www.facebook.com/7khmer
Fb page : Entertainment  And Knowledge

តែងមានដំណើរខ្វែងគំនិតគ្នាក៏មាន ហើយឱ្យជាហេតុមិនបានស្រុសស្រួលព្រមព្រៀងគ្នា ។ ខ្លះជ្រុលរហូតដល់ទៅសំដែងអាកប្បកិរិយាមិនល្អមើល ខ្លះពោលនូវវាចារមិនពីរោះកាន់ផ្ដាទៅវិញទៅមក ។ តែក្នុងសង្គមក្ដី ក្នុងពួកគណៈក្ដី រមែងមានមេ មានបា គ្រូអាចារ្យ មាតាបិតា អធិមតីសំរាប់និយាយស្ដី ដឹកនាំអ្នកដែលជាសហការី ជាកូន ជាចៅនៅក្រោមបង្គាប់ ។ ដូច្នេះបើជនណាមួយប្រព្រឹត្តខុសច្បាប់ទម្លាប់ទំនៀប ឬវិន័យសិក្ខានោះ លោកអ្នកដែលជាប្រធាន ជាសហការីផងគ្នា អាចនឹងនិយាយរំលឹកដាស់តឿនគ្នាបាន តែគប្បីហៅរកយកមកនៅទីមួយស្ងាត់តែពីរនាក់សឹមនិយាយប្រាប់នូវទោសដែលខុស ប្រាប់នូវពាក្យសំដីដែលខ្លួនបានពោលលើសល្មសមិនសមការ ប្រាប់នូវកិរិយាដែលខ្លួនបានប្រព្រឹត្តកន្លងទៅហើយជាការមិនគួរគប្បី ។ ការរំលឹកដាស់តឿនម្ដងជាពីរដងហើយ អ្នកនោះពុំយកដំបូន្មានតាម នោះត្រូវលៃលកឈប់និយាយស្ដី ឬឈប់រាប់អានជាសហការី ក្នុងពួកក្នុងគណៈ ។ តែបើជាអ្នករាជការវិញលោកតែងធ្វើទណ្ឌកម្មតាមកម្រិតច្បាប់ដែលតាំងទុកមក ។

ចំណែកមាតា បិតា នឹងបុត្រ-ធីតាដែលនៅតូចៗ ការបន្ទោសស្ដី ប្រដៅពុំចាំបាច់រកទីស្ងាត់ទេ ឃើញទាស់ខុសត្រង់ណាត្រូវកុំបណ្ដែតបណ្ដោយឱ្យខុសសិនចុះព្រោះថាក្មេងពុំទាន់ដឹងខុស ត្រូវយ៉ាងនេះត្រឡប់ទៅជាពុំប្រសើរវិញទេ ។ ដ្បិតធម្មជាតិក្មេងតែបណ្ដោយឱ្យឡើងដៃ នេះកាន់តែភ្លើតភ្លើនឥតល្បប ឥតសណ្ដាប់ធ្នាប់ខូចប្លុកពាអស់ ម្លោះហើយទម្លាប់នោះដុះជាប់ក្នុងសណ្ដានចិត្ត ដល់ចាស់ទៅក៏នៅតែមិនដឹងខុសត្រូវដូចពីក្មេងដរាបមក ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

តែចំណែកមនុស្សដែលសន្មតថាជាចាស់បានការហើយ ពីមាតាបិតាអោយបាន ភរិយា ស្វាមីហើយ ឬរាជការរើសយកទៅតាំងជាខ្ញុំរាជការ១រូបហើយ នោះការស្តី បន្ទោសដាស់តឿនរបស់មាតា បិតា គ្រូអាចារ្យ ចៅហ្វាយនាយ ប្រធាន អធិបតី គប្បី ធ្វើដោយសម្ងាត់ជាជរាប ទើបប្រសើរ ។

## ~និយាយកុហក~

បុរាណលោកចងជាពាក្យប្រដៅទុកថា "ពាក្យច្រើនភូតចាញ់អាត្មា"

នេះបានសេចក្តីថា អ្នកឯណាច្រើនប្រើពាក្យសំដីនិយាយភូតភរអ្នកនោះទោះ ជាមាន យសសក្តិខ្ពង់ខ្ពស់ក្តី មានជាតិ ត្រកូលខ្ពង់ខ្ពស់ក្តី ដោយសារប្រើសំដីវៀចវេរ មិនត្រង់ ត្រឹមត្រូវ ត្រឡប់ទៅជាមនុស្សថោកទាបទៅវិញ ។ បើគេស្គាល់ច្បាស់ ថាជាមនុស្ស ច្រើននិយាយកុហកបញ្ឆោតគេហើយ ទោះខ្លួននិយាយត្រង់ក៏គេមិនជឿ ខ្លះគេមិនទាំង ស្តាប់ផង ខ្លះទៀតគេក្រោកចោលមិននិយាយផង ។ យ៉ាងនេះហើយ ទើបលោកឱ្យឈ្មោះថា "ពាក្យច្រើនភូត ចាញ់អាត្មា" ។

ឯការនិយាយកុហកនេះ បើកាលណាអ្នកទាំងពួងដេញគំនិតទាន់ នោះក៏នឹង កើតសេចក្តីអៀនខ្មាស់ចំពោះមុខមហាជនក្រៃលែងទៅទៀត ។

* * * * *

www.facebook.com/7khmer
Fb page : Entertainment And Knowledge

# -និយាយកាត់-

ដំណើរនិយាយកាត់គេឯងរាល់គ្នា ដែលគេកំពុងប្រស្រ័យគ្នានូវការផ្សេងៗ ជាកិរិយាមិនសមគួរទេ គេអាចចាប់ហេតុ ឬ សំគាល់ក្នុងចិត្តគេបានថា យើងជាបនុស្សព្រហើន បំនចេះគារវកិច្ចក្នុងការនិយាយស្តី ។

ឧទាហរណ៍ទី១- បើយើងមានការពីគ្រោះជជែករកខុសត្រូវជាមួយនឹងមិត្រម្នាក់ ឬជនពេកបួយ នោះគប្បីទុកពេលចែកគ្នានិយាយបរិយាយម្តងម្នាក់ មិនត្រូវកាត់សេចក្តីដែលគេកំពុងអធិប្បាយឱ្យដាច់ទេ ។ តែបើយើងត្រូវការកាត់ដើម្បីកុំឱ្យវែងសេចក្តីនោះយើងគប្បីសូមទោសគ្នាជាមុនថា "ខ្ញុំសូមទោស សូមកាត់សេចក្តីលោកអ្នក ព្រោះរឿងនេះដូច្នេះវិញទេ" ។

២- គេកំពុងនិយាយគ្នា យើងមានការងារជាប្រញាប់ត្រូវប្រាប់អ្នកមួយក្នុងចំណោមនោះៗយើងត្រូវសុំទោសអ្នកទាំងឡាយជាមុនថា "ខ្ញុំសូមទោសអស់លោកអ្នក សូមនិយាយបន្តិច នឹងអស់លោកអ្នកនោះ អ្នកនោះ ។ រួចយើងនាំគ្នាចេញពីចំណោមគេមករកទី ១ ទៀតនិយាយគ្នា យ៉ាងនេះទើបសមគួរ ។

៣- បើចៅហ្វាយនាយ គ្រូអាចារ្យលោកនិយាយគ្នាអំពីការអ្វីមួយ ហើយដោយបានលោកខ្លះអធិប្បាយដោយភាន់ច្រឡំ ។ យើងក៏នៅ ១ទីនោះដែរ យើងបានដឹងជាក់ច្បាស់នូវរឿងនោះ ៗបើឥតលោកណាមួយសួរដណ្តឹងមកទេ យើងជាអ្នកតូចពុំគប្បីឆ្លើយកាត់ទៅទេ ព្រោះការឆ្លើយកាត់ឥតបានគេសួរ ហាក់ដូចជាមើលងាយលោកអ្នកនិយាយដោយភាន់ច្រឡំនោះ ឬហាក់ដូចនិយាយដើម្បីផ្ចាញ់ផ្ចាល ។ ដូច្នេះការនិយាយ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចាត់គេជាអំពើមិនល្អ មិនសមគួរ មិនគោរពដល់គេឯងដែលយើងនិយាយកាត់ទៅនោះ ។

## និយាយនៅពេលបរិភោគអាហារ

យើងរាល់គ្នាមានបំណងដូចៗគ្នាទាំងអស់ នៅរាល់ពេលដែលបរិភោគអាហារគឺប្រាថ្នាចង់បានតែម្ហូបដែលមានឱជារសឆ្ងាញ់ពិសា ប្រាថ្នាឱ្យតែត្រូវមាត់ទើបសុខចិត្តសុខកាយសប្បាយរីករាយ ។

ក៏ប៉ុន្តែ បើបានអាហារឆ្ងាញ់ពិសាយ៉ាងណាក៏ដោយ យើងនឹងអាស្រ័យក៏ពុំបានលេបពុំរួច រសជាតិអាហារនោះត្រឡប់ជាមិនឆ្ងាញ់ មិនត្រូវមាត់មៅវិញ ។ ទោសនេះបណ្តាលមកពីហេតុផ្សេងៗគឺ :

១- កើតឡើងអំពីយើងមានជម្ងឺនៅក្នុងខ្លួន ។

២- កើតឡើងអំពីទោសៈក្រោធខឹងមុនពេលបរិភោគអាហារ ឬ នៅពេលកំពុងបរិភោគ ។

៣- កើតឡើងអំពីទុក្ខសោកសង្រេងសង្រៃ ។

៤- កើតឡើងអំពីសេចក្តីទោមនស្សព្រួយចង្អៀតចិត្ត ។

៥- កើតឡើងអំពីសេចក្តីខ្ពើមរអើមដោយឃើញរបស់ស្មោគគ្រោក ឬដោយធុំ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក្លិនអសោចិ៍ស្អុយឆ្អេះឆ្អាបដែលមិនជាទីពេញចិត្ត ឬដោយមិនធ្លាប់ធន់ទ្រាំនឹងវត្ថុក្រខ្វក់នោះសោះ ។

ដូច្នេះនៅពេលបរិភោគអាហារ ដែលរួបរួមជនរួបរង់រួមតុជាមួយគ្នាច្រើនក្នុងក្រុមគ្រួសារនៅក្នុងទីប្រជុំមិត្រភក្តិក្ដី នៅក្នុងទីប្រជុំញាតិសាច់សាលោហិតព្រៀងលានក្ដី..... ។ល។

យើងគប្បីចៀសវាងពោលពាក្យដែលធ្វើឱ្យគេឯងលេបអាហារមិនរួច ដោយសំដីរបស់យើងមិនពីរោះបង្កើតឡើងនូវទោសដូចសំដែងមកហើយខាងលើ ។

*គឺ មិនត្រូវនិយាយនូវពាក្យ :*

១- ចាកដោតឱ្យគេក្រោធខឹង

២- រំលឹកអំពីទុក្ខសោកសង្រេងសង្រែផ្សេងៗ ។

៣- សំដីអសុរសធ្វើឱ្យគេទោមនស្សចង្អៀតចិត្ត ។

៤- ដំណាលអំពីវត្ថុក្រខ្វក់ដែលគួរខ្ពើម ដូចជាសាកអសុភ លាមក ..... ។ល។

• យើងគប្បីនិយាយ សំណេះសំណាលអំពីកាលដែលយើងសប្បាយរីករាយ ឬពីរឿងត្លុកកំប្លែងលេងប្រឡែងដោយពាក្យគ្រហាច់ទៅមកកាន់គ្នា..... ដើម្បីបំភ្លេចនូវសេចក្ដីព្រួយតែរៀងខ្លួន ម្ល៉ោះសមនឹងបរិភោគក៏បានច្រើន ទោះជាអាហារពុំសូវឆ្ងាញ់ពីសារក៏កង់បានគ្រាន់បើជាជាងលេបទាំងទុក្ខទោមនុស្សទាស់ចិត្តនឹងគេ ឬដោយខ្ពើមរអើម ។

(នៅមានភាគទី ២ តទៅទៀត)

www.facebook.com/7khmer
Fb page : Entertainment And Knowledge




ឈាង ជាឈីន

មានលក់ដុំ និងរាយនៅតូបលេខ 50,15,43 ផ្សារអូរឬស្សី

ទំនាក់ទំនងទូរស័ព្ទលេខ: 012 777 566 / 012 544440

Books World

www.facebook.com/7khmer
Fb page : Entertainment And Knowledge